ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-May-2017, 11:13
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២៦៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី
*(Mr. Matthew Mccarthy)*
កញ្ញា ជា ស៊ីវហ៉ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង
លោក វាំងសង់ វ៉ាយល៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*
លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សួន វិសាល
លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ស្រ៊ា រតនះ | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី អ៊ុង សារឿន (2-TCCP-980) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី អ៊ុង សារឿន ឬ អ៊ឹម សារឿន** (2-TCCP-980)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ទំព័រ ២

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ទំព័រ ៥

សួរដោយលោក ស្រ៊ា រតនៈ ផ្តើមពី ........................................ទំព័រ ១៥

សួរដោយលោក វាំងសង់ វ៉ាយដ៏ ដេស្នាឯល ផ្តើមពី ........................................ទំព័រ ២១

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី........................................ទំព័រ ២៣

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........................................ទំព័រ ២៧

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........................................ទំព័រ ៣២

សួរដោយកញ្ញា អង់តា ហ្គិសសេ ផ្តើមពី........................................ទំព័រ ៤០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-980។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះបានកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះមានរហស្សនាម 2-TCCP-980។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានវត្តមានរួចហើយនៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:០២:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនា-ការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពមិនអំណោយផលឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាពេលខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៦ ខែមីនា ២០១៥។ មេធាវីការពារក្តី

របស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការបង្ហាញ ឬក៏ដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៣:៥២]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា សុខភាពរបស់ជនជាប់ចោទ នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ ឈឺក្បាល វិលមុខ មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ដោយផ្អែកលើមូលដ្ឋាននេះ និងដោយយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-980 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៧:១៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី? លោកស្រីឈ្មោះអី?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ អ៊ុង សារឿន នៅឃុំ -- ភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** លោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំបានដែរទេ?

**ឆ៖** ខ្ញុំកើតឆ្នាំ១៩៥៥ ប៉ុន្តែអត់ចាំថ្ងៃខែទេ។

**ស៖** បាទ អរគុណ ហើយចុះទីលំនៅ ទីកន្លែងកំណើតរបស់លោកស្រីនៅទីកន្លែងណា?

**ឆ៖** ទីលំនៅខ្ញុំសព្វថ្ងៃនៅភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវដដែល។

**ស៖** យើងសួរទីកន្លែងកំណើត កើត លោកស្រីកើតនៅទីកន្លែងណា? ទីកន្លែងដូចគ្នានឹងទីលំនៅបច្ចុប្បន្នហ្នឹង ឬក៏កន្លែងផ្សេង?

**ឆ៖** កើតដូចគ្នា។

**ស៖** ទីកន្លែងកំណើត គឺដូចគ្នានឹងទីលំដ្ឋានបច្ចុប្បន្នសព្វថ្ងៃនេះ អ៊ីចឹង?

**ឆ៖** ចាស។

**ស៖** អរគុណ ហើយលោកស្រីប្រកបមុខរបររកស៊ីធ្វើអីសព្វថ្ងៃនេះ?

**ឆ៖** ចាស ខ្ញុំធ្វើស្រែ កសិករ។

**ស៖** ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ តើលោកស្រីរស់នៅទីកន្លែងណា ហើយប្រកបមុខរបរអ្វី?

[០៩:០៩:៣៩]

**ឆ៖** កាលពីឆ្នាំ៧៩ ខ្ញុំនៅភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវដដែល។

**ស៖** និយាយរួមក្នុងៗរបបកម្ពុជាប្រជាធិបតេយ្យ ពី១៧ ខែមេសា ៧៥ ដល់ ០៦ មករា ៧៩ តើលោកស្រីរស់នៅទីកន្លែងណា ហើយធ្វើអ្វី?

**ឆ៖** ចាស ខ្ញុំ៧៥ ខ្ញុំនៅតាកែវ។ ខ្ញុំ គ្រួសារខ្ញុំធ្វើទាហានជំនាន់ លន់ នល់។ ខ្ញុំនៅលក់នំអាកោ នំក្រូចនៅផ្សារតាកែវ ផ្សារណាត់។

**ស៖** ក្រោយរំដោះទីក្រុងភ្នំពេញ ១៧ មេសា ៧៥ រហូតដល់ឆ្នាំខែមករា ៧៩ តើលោកស្រីរស់នៅទីកន្លែងណា ហើយធ្វើអ្វីដែរ?

**ឆ៖** អាហ្នឹង ខ្ញុំធ្វើស្រែដែរ ៧៩។

**ស៖** ឪពុករបស់លោកស្រីឈ្មោះអី ហើយម្ដាយរបស់លោកស្រីគាត់ឈ្មោះអីដែរ?

**ឆ៖** ឪពុកឈ្មោះ គីម ពុំ, ម្ដាយឈ្មោះ សុខ សឿង។

**ស៖** អរគុណ ហើយប្ដីរបស់លោកស្រី គាត់ឈ្មោះអី ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** គ្រួសារខ្ញុំឈ្មោះ អ៊ុយ មុត, កូនម្នាក់។

[០៩:១១:៤៦]

**ស៖** ហើយលោកស្រី អ៊ុំង សារឿន តើលោកស្រីចេះអក្សរខ្មែរទេ ដូចចេះអាន ចេះសរសេរអក្សរខ្មែរដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជា -- លោកស្រី អ៊ុំង សារឿន ជាចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកស្រីក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីអាចមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា ស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។ នេះយើងប្រាប់ជាមុន ដើម្បីលោកស្រីមានឱកាសក្នុងការពិចារណា ហើយរៀបចំនូវគំនិត និងប្រាជ្ញាស្មារតីក្នុងការថ្លែងរៀបរាប់នៅពេលចុងក្រោយនៃការផ្ដល់សក្ខីកម្មរបស់លោកស្រីនៅព្រឹកនេះ។

បាទ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំង សារឿន មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយអង្គជំនុំជម្រះសូមជម្រាបបញ្ជាក់ថា សហព្រះរាជអាជ្ញា -- សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីរួមនឹងសហព្រះរាជអាជ្ញាមានរយៈពេលមួយវគ្គសវនាការក្នុងការសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គឺត្រឹមពេលនេះរហូតដល់ពេលសម្រាកនៅពាក់កណ្ដាលព្រឹកនេះ។ សូមអញ្ជើញ!

[០៩:១៣:២០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ជម្រាបសួរអស់លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

01468752



**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍**

**ស៖** ជម្រាបសួរលោកស្រី ដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំចាប់ផ្តើមសួរសំណួរលោកស្រីមួយចំនួនដើម្បីឲ្យដឹងពីប្រវត្តិរបស់លោកស្រីចាប់ពីខែមេសា ឆ្នាំ១៩៧៥។ លោកស្រីបានជម្រាបជូនលោកប្រធានថា លោកស្រីរស់នៅខេត្តតាកែវនៅ<ខែមេសា> ឆ្នាំ១៩៧៥។ អ៊ីចឹងតើមានរឿងអីកើតឡើងចាប់ពី<ពេលនោះមក>? លោកស្ថិតរស់នៅតាកែវដដែល ឬក៏លោកស្រីចេញទៅកន្លែងណាផ្សេង?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស នាងខ្ញុំពីឆ្នាំ៧៥ ខ្ញុំជម្លៀសទៅចេញពីខេត្តតាកែវជម្លៀសទៅវត្តចំប៉ា ចំប៉ាលើក។ នាងខ្ញុំនៅ ចេញទាំងអស់នៅរួមគ្រួសារ នៅមូលប្រជាជន ១៧មេសា នៅនឹងខេត្តតាកែវ នៅវត្តចំប៉ា។ ដល់ទៅពេលនាងខ្ញុំបានក្នុមួយអាទិត្យ បានជម្លៀសមកនៅភូមិព្រៃឈើទាល១ ស្រុកត្រាំកក់ដែរកាលនោះ ខាងកើតវត្តចំប៉ា។ បាននៅកន្លែងភូមិព្រៃឈើទាលហ្នឹងចំនួនជាកន្លះខែ នាងខ្ញុំឲ្យមកចុះនៅនឹងឃុំលាយបូរ ភូមិអង្គនរាយណ៍ ឃុំលាយបូរ ស្រុកត្រាំកក់។ ដល់តែឆ្នាំ៧៦ នាងខ្ញុំ អង្គការប្រមូលអ្នក១៧ឲ្យទៅនៅភូមិជ្រៃជម្រៅ ឃុំលាយបូរ ស្រុកត្រាំកក់។ អ្នក១៧ ទី៣ ១៧មេសាហ្នឹង។ ដល់ឆ្នាំ៧៦ នាងខ្ញុំនៅកងប្រមូលផ្តុំក្នុងភូមិ។ ដល់ឆ្នាំ១៩៧៧ នាងខ្ញុំនៅកងចល័ត១រែកដី ធ្វើប្រឡាយ។ នាងខ្ញុំលីស៊ីម៉ង់ត៍នៅវ៉ារទេះភ្លើង មួយក្រុមគ្នា១២នាក់ ស្រី១។

[០៩:១៥:៥៩]

យប់អង្គការស្នើឲ្យជួយជំនួយលីស៊ីម៉ង់ត៍ អំបិល ដាក់ឃ្លាំង។ ដល់ឆ្នាំ១៩៧៧ នាងខ្ញុំ មិត្តភក្តិគាត់ប៉ិនលួចអាហារ។ គាត់ហេរ គាត់លួចយកទៅហូប ទាន់ អង្គការទាន់ យកចាប់ពីរនាក់ទៅបាត់ យកទៅរំលោភបាត់ដល់ថ្ងៃ -- បាត់រហូតទល់សព្វថ្ងៃ។ យកសម្លាប់បាត់ទៅ អត់ឃើញមកវិញ។

ដល់តែនាងខ្ញុំ ៧៨ អង្គការយកខ្ញុំទៅភ្នំ -- ចម្ការសៀង នៅធ្វើនៅចម្ការសៀងទៀត ប្រឡាយទំនប់ និងអាងទំនប់ចម្ការសៀង។ ទារុណកម្មខ្ញុំនៅហ្នឹង នារី១៧ហ្នឹងបីនាក់ ឲ្យនៅទារុណកម្មនៅហ្នឹង។ ដល់តែពេលក្រោយ នាងខ្ញុំចូល៧៩ បាននាងខ្ញុំ កងទ័ពវៀតណាមទៅរំដោះ។ គេមានឡានមានអី គេដឹកយកទៅបន្ត១ទៅ ដឹងទៅណា។ នាងខ្ញុំលួចរត់ចេញមកទិសខាងកើតវិញ។ នាងខ្ញុំបានកំសៀវទឹកមួយយកមកដាំបាយហូប ដួសដាក់។

**ស៖** ខ្ញុំសូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវ ខ្ញុំសូមត្រឡប់មកក្រោយបន្តិច

ហើយដែលចោទសំណួរជាក់លាក់ដល់លោកស្រី ដែលទាក់ទងទៅនឹងប្រវត្តិដែលលោកស្រីទើបនឹងបានរៀបរាប់អម្បាញ់មិញនេះ។ ខ្ញុំចង់ដឹងថា តើនៅពេលណាលោកស្រី ត្រូវបានបំបែកចេញពីក្រុមគ្រួសាររបស់លោកស្រី? ចង់និយាយថាចន្លោះពីតាកែវ ទៅដល់ដើមឆ្នាំ១៩៧៩។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកស្រីត្រូវបានគេបំបែកចេញពីក្រុមគ្រួសារលោកស្រី នៅពេលណាជាក់លាក់?

**ឆ៖** ចាស ពីឆ្នាំ៧៦។

**ស៖** តើនៅពេលនោះ លោកស្រីបានទៅដល់ឃុំលាយបូរហើយឬនៅ?

**ឆ៖** ចាស នាងខ្ញុំដល់ហើយ។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាលោកស្រីទៅដល់ឃុំលាយបូរនោះជាមួយក្រុមគ្រួសារ មានបងប្អូនប៉ុន្មាននាក់នៅជាមួយ? <ហើយពេលបែកគ្នានោះ បែកពីនរណាខ្លះ?> ហើយពេលនោះ លោកស្រីរៀបការហើយឬនៅ? ហើយមានបងប្អូនប៉ុន្មាននាក់? ហើយគេបំបែកលោកស្រីចេញ <តើលោកស្រី>មានកូនប៉ុន្មាននាក់? ហើយគេបំបែកលោកស្រីចេញនៅពេលណា?

**ឆ៖** ចាសបំបែកខ្ញុំពីឆ្នាំ៧៦ហ្នឹង កូនម្នាក់។ គ្រួសារខ្ញុំនៅកង បែកគ្នាៗបាត់រហូត ដល់មកសព្វថ្ងៃហ្នឹងអត់ឃើញ។

[០៩:២០:០០]

**ស៖** តើលោកស្រីមានកូនដែរឬទេ នៅពេលនោះ?

**ឆ៖** ចាស កូនមួយ–កូនប្រុស។ កូនអាយុមួយខួប ស្លាប់ទៀត។

**ស៖** តើ<នៅពេលនោះ>លោកស្រីត្រូវបានគេបំបែកចេញពីកូនប្រុសលោកស្រី ដែរឬទេ? តើហេតុដូចម្តេចបានលោកស្រីដឹងថា កូនប្រុសរបស់លោកស្រីហ្នឹងស្លាប់ហើយ?

**ឆ៖** ចាស កូនប្រុសខ្ញុំហ្នឹងនៅជាមួយវាទៅកងប្រមូលផ្តុំយកទៅដាក់ជាមួយយាយៗ។ ឱ្យយាយមើល យាយធ្វើការអត់កើតឱ្យយាយមើល។ ហើយកូនប្រុសខ្ញុំហ្នឹង យាយៗគាត់ប្រាប់ថា កើតកញ្ជ្រិលស្លាប់ទៅ។ នាងខ្ញុំនៅកងប្រមូលផ្តុំ។

**ស៖** បាទ សូមអរគុណ។ ហើយលោកស្រីបានប្រាប់ថា លោកស្រីចូលធ្វើការនៅក្នុងកង២ ចាប់ពីពេលលោកស្រីទៅដល់ឃុំលាយបូរនៅឆ្នាំ៧៦ នៅក្នុងក្រុមមួយ ហើយចាប់ពីឆ្នាំ១៩៧៧ ទៅនៅក្នុងកងចល័ត។ ខ្ញុំសូមចោទសំណួរទៅលើកងទី១ ដែលលោកស្រីធ្វើការនៅក្នុងហ្នឹង។ អ៊ីចឹងតើ កងទី១ ហ្នឹងមានសមាជិកជាអ្នកណាខ្លះ?

**ឆ៖** ចាស កងទី១ សុទ្ធអ្នកមូលដ្ឋាន។ កងទី២ អ្នកពាក់ព័ន្ធបងប្អូននៅ១៧។ កងទី៣ អ្នក១៧មេសា ចេញពី ៧៥។

[០៩:២២:១៥]

**ស៖** បើតាមការចងចាំរបស់លោកស្រី តើប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋានហ្នឹង ធ្វើការជាមួយគ្នា ឬក៏<រស់នៅ>ដាច់ពីគ្នា?

**ឆ៖** ចាស ធ្វើការដាច់ពីគ្នា ចែកតាមកង តាមក្រុមផ្សេងគ្នា។

**ស៖** តើលក្ខខណ្ឌការងារនៅក្នុងក្រុមលោកស្រីធ្វើការនៅក្នុងឆ្នាំ១៩៧៦ ហ្នឹង ហើយនិងក្រុមមួយទៀត កងមួយទៀតដែលគេហៅថាកងចល័ត ដែលគេបញ្ជូនលោកស្រីទៅធ្វើការនៅឆ្នាំ១៩៧៧នោះ ខ្ញុំសួរថាតើលក្ខខណ្ឌរវាងកងទាំងពីរហ្នឹងខុសគ្នាដែរឬទេ? កងដំបូងដែលលោកស្រីធ្វើការ ហើយនិងបន្ទាប់មកឆ្នាំ៧៧ លោកស្រីធ្វើការនៅក្នុងកងចល័ត សួរថាលក្ខខណ្ឌការងារខុសគ្នាឬក៏យ៉ាងណា?

**ឆ៖** កាល៧៧ហ្នឹង ខ្ញុំនៅកងចល័តហ្នឹង អាហ្នឹងរើសកម្លាំងក្មេងៗ។ ខ្ញុំចល័តហ្នឹងរែកដី ធ្វើប្រឡាយទំនប់ កម្លាំងក្មេងយកឲ្យទៅរែកងចល័ត។

**ស៖** នៅពេលដែលលោកស្រីត្រូវបានគេបញ្ជូលឲ្យធ្វើការនៅក្នុងកងចល័ត នៅក្នុងឆ្នាំ១៩៧៧ តើលោកស្រីធ្លាប់បានឃើញមនុស្សដែលលោកស្រីចាត់ទុកថាជាអ្នកធំ ហើយចូលទៅធ្វើទស្សនកិច្ចនៅការដ្ឋានដែលលោកស្រីធ្វើការដែរឬទេ?

[០៩:២៤:២០]

**ឆ៖** ចាស ខ្ញុំពីមុនហ្នឹង មិត្តប្រធានកងខ្ញុំហ្នឹងគាត់ប្រាប់ គាត់ថា "មានអង្គការមក"។ ហើយដល់ពេលក្រោយបានពីរថ្ងៃហ្នឹងឃើញមក ប៉ុនខ្ញុំស្គាល់ជាក់តាម៉ុក ហើយ តាសាន។ ហើយ តានូវ គាត់គណៈឃុំលាយបូរពីមុនហ្នឹង។ ហើយតាៗបីហ្នឹង ខ្ញុំឃើញតែមួយភ្លែតទេ ខ្ញុំអត់សូវចងចាំទេ។

**ស៖** តើលោកស្រីអាចចាំទេថា តើនៅពេលណាដែរ ដែលគាត់មកមើលការដ្ឋានហ្នឹង?

**ឆ៖** ចាស ឆ្នាំ៧៧ ប៉ុនមិនដឹងខែប៉ុន្មានៗទេ ខ្ញុំអត់ចងចាំ។ ខ្ញុំៗពេលកម្មខ្ញុំធ្វើប្រឡាយហ្នឹង ខ្ញុំរែកដីធ្វើស្ពានីយអូរចំបក់ហ្នឹង នៅរ៉ាហ្នឹង ខ្ញុំបែរមុខទៅកើត ហើយខ្ញុំឃើញឡានហ្នឹងបែរមុខមកលិច ប៉ុនខ្ញុំស្គាល់ តាម៉ុក គាត់ជិះឡានហ្ស៊ីប ហើយឃើញឡានមួយទៀត ខ្ញុំមិនដឹងឡានម៉ាកអីៗ ខ្ញុំអត់ស្គាល់។ ដល់ពេលក្រោយគាត់អញ្ជើញទៅវិញអស់ បានមិត្តយឿនហ្នឹង គាត់ខ្សឹបប្រាប់ឈ្មោះតាៗហ្នឹងបានខ្ញុំ -- អ៊ូ! ខ្ញុំអត់ដែលបានឃើញទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកស្រីមានចាំឈ្មោះដែល យឿន ហ្នឹងប្រាប់លោកស្រីដែរឬទេ?

**ឆ៖** ចាស ខ្ញុំចាំ ប៉ុន្តែឥឡូវគាត់ស្លាប់ហើយ។

**ស៖** ប៉ុន្តែសំណួរខ្ញុំអម្បាញ់មិញនេះ មិនមែនអ៊ីចឹងទេ លោកស្រីបានប្រាប់ថា យឿន ហ្នឹងបាន ប្រាប់ឈ្មោះអ្នកដែល<>មកមើលការដ្ឋានហ្នឹង អ៊ីចឹងខ្ញុំចង់សួរលោកថា លោកស្រីថាតើយឿនដែល ស្លាប់ហើយនោះគាត់បានប្រាប់ឈ្មោះ<អ្នកណា>ខ្លះ? យឿន ដែលប្រាប់នោះណា ប្រាប់ឈ្មោះអ្នកណា ខ្លះអ្នកដែលមកធ្វើទស្សនកិច្ចហ្នឹង? មានអ្នកណាខ្លះសូមជួយប្រាប់ឈ្មោះដល់តុលាការ។

**ឆ៖** ចាស គាត់ប្រាប់ថាឈ្មោះតា នួន ជា, តា ខៀវ សំផន, ហើយនិងតា ប៉ុល ពត។ ប៉ុន ខ្ញុំ អត់ចងចាំទេណា ខ្ញុំអត់ស្គាល់គាត់ទេ ពេលដែលគាត់ចេញទៅវិញ។

**ស៖** សូមអរគុណ។ តើលោកស្រីស្គាល់ឈ្មោះ ខៀវ សំផន មុនពេលដែល <យឿន>នេះប្រាប់ លោកស្រីនៅថ្ងៃដែលគាត់ចុះមកមើលការដ្ឋានហ្នឹងទេ ឬលោកស្រីបានឮឈ្មោះ ខៀវ សំផន ហ្នឹងមុន ពេលហ្នឹងឬក៏ទើបតែឮនៅពេលដែលគាត់ចុះមកមើលការដ្ឋានហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំពីមុនខ្ញុំឮតែឈ្មោះគាត់មួយទេ ពីឮខ្ញុំគាត់អានកាសែតធ្វើគ្រូ។ បើតាៗពីរនេះ ខ្ញុំអត់ ដែលឮទេ។ ឮតែឈ្មោះតាខៀវ សំផនមួយទេ ប៉ុនខ្ញុំអត់ស្គាល់ដែរ អាហ្នឹងមាគាត់ធ្វើគ្រូ គាត់អាន កាសែតប្រាប់។

[០៩:២៨:២៩]

**ស៖** តើកាលហ្នឹងលោកស្រីមានស្គាល់ឈ្មោះ ប៉ុល ពតទេ? កាលណោះធ្លាប់ឮឈ្មោះ ប៉ុល ពត មុនពេលដែលប្រធានកងរបស់លោកស្រីគឺ <យឿន> ហ្នឹងប្រាប់ឈ្មោះ ប៉ុល ពត ដែរឬទេ?

**ឆ៖** ខ្ញុំឮប៉ុន្តែខ្ញុំអត់ដែលស្គាល់ ឮតែ ប៉ុល ពតៗ ខ្ញុំអត់ដែលស្គាល់។

**ស៖** ជាចុងបញ្ចប់ឈ្មោះ នួន ជានេះ លោកស្រីស្គាល់ឈ្មោះ នួន ជានេះមុន ឮឈ្មោះ នួន ជា នេះមុនពេលដែល <យឿន> នោះប្រាប់លោកស្រីទៀតឬក៏យ៉ាងណា?

**ឆ៖** ចាស ពីមុនអត់ ខ្ញុំអត់ដែលឮ ទើបតែឮ។ នាងខ្ញុំឮតែ៧៧ ហ្នឹង។

**ស៖** ហេតុដូចម្តេចបានជាលោកស្រីដឹងថាពួកគាត់ទាំងអស់គ្នាហ្នឹងជាអ្នកធំដែលមកមើល ការដ្ឋានហ្នឹង?

**ឆ៖** ខ្ញុំអត់ដឹងគាត់អ្នកធំទេ ខ្ញុំដឹងតែអង្គការៗតំណាងកងប្រាប់ថាអង្គការមក ឲ្យមិត្តយើងខំធ្វើ ការឲ្យលឿន។ ខ្ញុំស្គាល់តែតាម៉ុក ហើយតាសាន ដឹងអ្នកធំតែពីរហ្នឹង។ ហើយ តានូវ ខ្ញុំដឹងថាមេឃុំ។

**ស៖** ខ្ញុំសូមអរគុណ។ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេអំពីការប្រព្រឹត្តទៅនៃទស្សនកិច្ចហ្នឹង? <លោកស្រីនិយាយអំពី>ឡានទី១ <គឺឡានហ្ស៊ីប ដែល>មានតាម៉ុកជិះឡានហ្នឹង ហើយបន្ទាប់មកមានឡានមួយទៀត។ អ៊ីចឹងលោកស្រីអាចជម្រាបជូនតុលាការដែរឬទេ ថាលោកស្រីបានឃើញអ្វីខ្លះនៅពេលថ្ងៃដែលពួកគាត់មកធ្វើទស្សនកិច្ចហ្នឹង?

**ឆ៖** ចាស ខ្ញុំឃើញទ័ពទៅទទួល ហើយនិងមេឃុំ ហើយនិងតំណាងកងគាត់ឡើងមកទទួល។ នាងខ្ញុំរែកដីឡើងចាក់ទំនប់ប្រឡាយហ្នឹង ចំនួនជា -- ខាងស្ដាំដៃ ជា៤-៥ម៉ែត្រពីនាងខ្ញុំ ៥-៦ម៉ែត្រអ៊ីហ្នឹងខាងស្ដាំដៃ។

**ស៖** តើមានមនុស្សប៉ុន្មាននាក់ធ្វើការជាមួយលោកស្រីនៅថ្ងៃនោះ ហើយតាមទម្លាប់នោះមានមនុស្សធ្វើការជាមួយលោកស្រីប៉ុន្មាននាក់ដែរនៅក្នុងឆ្នាំ១៩៧៧ ហ្នឹង?

**ឆ៖** ចាស ច្រើនប៉ុនចែកជាក្រុម មួយក្រុមនាងខ្ញុំមាន១២នាក់ កងប្រមូលផ្ដុំហ្នឹងច្រើន។ ខ្ញុំអត់ចងចាំប៉ុន្មានៗអត់ទេ ដឹងតែក្រុមមួយក្រុម ១២នាក់។

**ស៖** អ៊ីចឹងតើលោកស្រីចង់និយាយថា ថ្ងៃហ្នឹងមានក្រុមប្រមូលផ្ដុំហ្នឹងច្រើនដែលធ្វើការនៅលើការដ្ឋានហ្នឹង។ អ៊ីចឹងលោកស្រីអាចប្រាប់ចំនួនប្រហាក់ប្រហែលបានទេ ថាមានមនុស្សប៉ុន្មាននាក់ធ្វើការនៅថ្ងៃហ្នឹង?

**ឆ៖** មនុស្សច្រើនរាប់រយនាក់ នៅកងចល័តហ្នឹងរាប់រយ ប្រមូលជាកង។ ចែកជាក្រុម ១២ ប្រមូលកងរាប់រយនាក់។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមចោទសំណួរមួយចំនួនទៀតទាក់ទងទៅនឹងរបបអាហារ របស់លោកស្រីនៅពេលនោះ តើលោកស្រីហូបអីខ្លះនៅពេលនោះ។ <សូមលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះ តើលោកស្រីហូបអ្វីនៅក្នុងអំឡុងពេលនោះ> ខ្ញុំចង់និយាយពីនៅក្នុងឆ្នាំ៧៦ នៅពេលលោកស្រី <ចាត់តាំងឱ្យទៅធ្វើការនៅកងទី១ គឺនៅពេល>ទៅដល់លាយបូរភ្លាម តើគេឱ្យលោកស្រីហូបចុកយ៉ាងម៉េចដែរ?

**ឆ៖** ចាស កាលឆ្នាំ នាងខ្ញុំចូលដល់៧៦ ចែកអង្ករឱ្យដាំបាយហូបឯកជន ចែកអង្ករ មួយកំប៉ុងពីរនាក់ក្នុងមួយថ្ងៃ។

[០៩:៣៣:៥៧]

**ស៖** ហើយក្រោយឆ្នាំ១៩៧៦ នោះតើរបបហូបចុកនោះបានផ្លាស់ប្ដូរប្រែប្រួលដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំទៅនៅកងទៅ ហូបបបរ កងចល័តបបរប៉ិ ដួសវែក ដួសចែក។

**ស៖** តើចាប់ពីឆ្នាំ<១៩៧៧> នោះលោកស្រីមានរបបអាហារច្រើនជាងមុន ឬក៏តិចជាងមុន?

**ឆ៖** ចាស តិច។

**ស៖** តើលោកស្រីមានអត់ឃ្លានដែរឬទេ នៅក្នុងឆ្នាំ១៩៧៧ ហ្នឹង?

**ឆ៖** ចាស នាងខ្ញុំអត់ឃ្លាន ខ្ញុំទៅលួចដំឡូង ពោត យកមកហូប គេចាប់បានដែរ។ យកទៅកសាងថា "មិត្តយើងថ្ងៃក្រោយតែមានលួចទៀត ហ្នឹងលើកទី១ ដោះលែងឲ្យ លើកទី២ មិត្តយើងកសាងខ្លួន"។ ខ្ញុំកសាងខ្លួន អត់ លែងហ៊ានលួចទៅ ចេះតែទ្រាំអត់។ នៅលួចដែរ លួចតិចៗ ខ្ញុំដាក់ថ្នក់សំពត់ ដំឡូងអីមួយកង់ៗតិចៗហ្នឹង ដាក់ថ្នក់សំពត់ហូប អត់ហ៊ានលួចច្រើនដូចមុនទេ។

**ស៖** សូមអរគុណ។ តើនៅពេលនោះ លោកស្រីមានដឹងដែរឬទេថា តើប្រជាជន១៧មេសានោះត្រូវមានរបបហូបចុកដូចគ្នានឹងប្រជាជនមូលដ្ឋានដែរឬទេ?

**ឆ៖** ចាស អត់ទេ។ ប្រជាជនមូលដ្ឋានហូបបាយឆ្អែត ប្រជាជន១៧ ហូបបបរ។

**ស៖** សូមអរគុណ។ អម្បាញ់មិញលោកស្រីបានប្រាប់ឈ្មោះអតីតមេឃុំលាយបូរ លោកស្រីប្រាប់ថាឈ្មោះ តានូវ។ អ៊ីចឹង លោកស្រីអាចបញ្ជាក់បានដែរឬទេថាគាត់ហ្នឹងហើយឬជាមេឃុំលាយបូរនៅពេលដែលលោកស្រីទៅដល់ទៅធ្វើការនៅទីនោះ?

**ឆ៖** ចាស មេឃុំលាយបូរហ្នឹងមានបីនាក់។ មាន ប៉ុន្តែខ្ញុំអត់ដឹងតាជាប្រធាន ព្រោះខ្ញុំប្រជាជនអត់ដឹងទេ។ មានតានូវ, តាហួញ, តាកិ។

[០៩:៣៧:៣០]

**ស៖** លោកស្រីបានជម្រាបថាលោកស្រីស្គាល់ តានូវ។ អ៊ីចឹង សុំឲ្យលោកស្រីជម្រាបជូនតុលាការថា តើតានូវ ហ្នឹងចរិតគាត់យ៉ាងម៉េចដែរក្នុងឋានៈជាមេឃុំហ្នឹង? គាត់យ៉ាងម៉េចដែរ?

**ឆ៖** ចាស តានូវ ហ្នឹងគាត់កាច។ គាត់មកយក ឲ្យនីរសាសមកយកពូខ្ញុំ ដល់ហើយច្រឡំយកជាឪពុកមាខ្ញុំទៅ វៃបាក់ធ្មេញអស់ ដល់ហើយបាន "ហ៊ឺ! ច្រឡំ" ឲ្យគាត់មកវិញ។ ដល់ពេលក្រោយយកគាត់មកវិញ ហាមថា "តាឯងកុំមាត់ តែមាត់យកសម្លាប់អស់មួយពូជ"។ ឥឡូវគាត់នៅសព្វថ្ងៃអាយុ៩២ ហើយគាត់នៅ ហើយកូនគាត់យកទៅសម្លាប់បាត់ហើយ ធ្វើទាហាន។

**ស៖** សូមអរគុណ។ តើលោកស្រីមានព័ត៌មានអ្វីចង់ចែករំលែកដល់តុលាការដែរឬទេ ស្តីអំពីតានូវ? ចង់និយាយថាមុខងារគាត់ មុខការគាត់នៅក្នុងឃុំលាយបូរហ្នឹងគាត់ធ្វើអីខ្លះ?

**ឆ៖** ចាស ខ្ញុំអត់ដឹង នាងខ្ញុំ១៧ ខ្ញុំអត់ដឹង។ ដឹងតែគាត់មេឃុំ។

**ស៖** សូមអរគុណ។ អម្បាញ់មិញលោកស្រីបានជម្រាបជូនតុលាការថា ប្ដីរបស់លោកស្រីបាត់ខ្លួន ហើយគាត់ជាអតីតទាហានលន់ នល់។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើលោកស្រីបានដឹងថាមានរឿងអ្វីកើតឡើងចំពោះប្ដីលោកស្រីដែរឬទេ?

**ឆ៖** ចាស មានកាលពីជំនាន់ ៧៦-៧៧ហ្នឹង មានពួម្នាក់គាត់ទ័ត ទ័តប៉ុលពតហ្នឹង គាត់នៅយាមមន្ទីរឃុំឃាំងនៅអង្គតាសោម ស្រុកត្រាំកក់ហ្នឹង។ បញ្ជូនពីមេឃុំទៅ យកទៅដាក់កន្លែងមន្ទីរឃុំឃាំងអង្គតាសោម។ ចេញពីឈ្មោះពីអង្គតាសោមហ្នឹងទៅ យកទៅសម្លាប់នៅក្រាំងតាចាន់នេះ។ ឈ្មោះជឹម។

[០៩:៤០:០០]

**ស៖** ខ្ញុំដូចជាមិនយល់ការបកប្រែជាភាសាបារាំងទេ អ៊ីចឹងខ្ញុំសូមសួរសំណួរបន្តថាតើអ្នកដែលធ្វើការឲ្យខ្មែរក្រហម ដែលលោកស្រីនិយាយអម្បាញ់មិញនេះថាគាត់ហ្នឹងជាអ្នកយាមនៅអង្គតាសោមនោះ គាត់ហ្នឹងឈ្មោះអីដែរមនុស្សម្នាក់ហ្នឹង?

**ឆ៖** ចាស គាត់ឈ្មោះ ជឹម។

**ស៖** សូមអរគុណ។ តើជឹម នុ៎ងបានប្រាប់អ្វីខ្លះដល់លោកស្រីទាក់ទងនឹងរឿងប្ដីលោកស្រី?

**ឆ៖** ចាស ដល់ពេលក្រោយ គាត់ជួបថា មិនបាច់ចាំផ្លូវទេ ឈ្មោះ អ៊ុយ មុត ហ្នឹងយកទៅមន្ទីរឃុំឃាំងកន្លែងគាត់។ ហើយដល់ហើយឈ្មោះហ្នឹងបញ្ជូនទៅក្រាំងតាចាន់ហើយ។ គាត់បាននិយាយតែប៉ុណ្ណឹង។

**ស៖** តើ ជឹម ហ្នឹងអ្នកប្រាប់លោកស្រីយ៉ាងដូច្នេះ ឬក៏អ្នកណាផ្សេង?

**ឆ៖** មានមួយទៀត ឈ្មោះ ហ៊ូ គាត់ធ្វើទាហានជំនាន់ លន់ នល់ ដែរ គាត់ទៅជាប់គុកនៅក្រាំងតាចាន់ ប៉ុន្តែដល់៧៩ ហ្នឹងគាត់រួច គាត់អត់ស្លាប់។ គាត់ថា ឃើញជួបគ្នានៅក្រាំងតាចាន់ សម្លាប់ហើយ។ គាត់បានរួចមកវិញ។

**ស៖** លោកស្រីនិយាយអម្បាញ់មិញថា បុគ្គលរូបហ្នឹង លោកស្រីចង់និយាយថា និយាយពី អ៊ុយ មុត ឬក៏យ៉ាងណា? ថាប្ដីលោកស្រីហ្នឹង អ៊ុយ មុត ហ្នឹងយ៉ាងម៉េច? ព្រោះខ្ញុំឮតាមការបកប្រែមិនច្បាស់។

**ឆ៖** ចាស អ៊ុយ មុត ហ្នឹងគ្រួសាររបស់ខ្ញុំ ហើយ ហ៊ូ ហ្នឹងគាត់ជាប់គុកនៅក្រាំងតាចាន់ជាមួយ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

គ្នាទាហានជំនាន់ លន់ នល់។ គាត់ថា “កុំចាំមើលផ្លូវអី អ៊ុយ មុត ហ្នឹងស្លាប់ហើយ”។ គាត់បានរួចមកវិញ ថារំដោះទាន់។

[០៩:៤៣:០៨]

**ស៖** ដើម្បីឲ្យច្បាស់តែម្តង គឺលោកស្រីបានឆ្លើយថា ជឹម ដែលជាអ្នកយាមនៅគុកអង្គតាសោម នេះ ខ្ញុំសួរចង់ដឹងថាតើ ជឹម ហ្នឹងមានបានប្រាប់អីលោកស្រីដែរឬទេ អំពីថាតើមានរឿងអីកើតឡើងដល់ប្តីលោកស្រី?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរលោក លោកស្រីចៅក្រម។ នៅពេលដែលទទួលយកសំណួរពាក់ព័ន្ធទៅនឹងផ្នែកនៃការជំនុំជម្រះក្នុងវគ្គនេះ <ខ្ញុំសូមធ្វើការកត់សម្គាល់ថា ឥឡូវនេះការតាំងសំណួរបានចំណាយពេលអស់>កន្លះម៉ោង ហើយពីរនាទីក្នុងរយៈពេលសាមសិបនេះ គឺសួរតែ ថាហេតុអ្វីបានជាដើមបណ្តឹងរដ្ឋប្បវេ-ណីត្រូវបានកោះហៅឲ្យមកចូលចំពោះមុខអង្គជំនុំជម្រះនេះ។ <នេះជាពេលចុងក្រោយ ដែលយើងយល់ស្របចំពោះសំណើនេះ។> បរិបទនៃសំណើសុំជាសំណើសុំបន្ទាន់ ហើយសួរទៅសាក្សីរូបនេះ ទៅលើមេដឹកនាំជាន់ខ្ពស់<ដែលជាសមាជិកគណៈមជ្ឈិម>។ខ្ញុំឃើញ<>ហាក់បីដូចជា<មានការព្យាយាម>បញ្ចុកពាក្យទៅឲ្យសាក្សីរូប<នេះ គឺសុទ្ធតែភស្តុតាងថ្មីទាំងអស់>។ ការតាំងសំណួរបែបនេះគឺថាមិនសមស្រប<ទៅតាមនីតិវិធី>ទេ។ ខ្ញុំ<យល់>ថាសំណួរនេះវាពាក់ព័ន្ធ<> ប៉ុន្តែមិនមានហេតុផលអីត្រូវហៅដើមបណ្តឹងរដ្ឋប្បវេណីមកនៅពេលនេះទេ។

[០៩:៤៤:៤៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ យើងបានស្នើឲ្យមានការស្តាប់សក្ខីកម្មគាត់នេះ អនុលោមទៅតាមវិធាន៨៧(៤) មូលហេតុដែលយើងស្នើនេះ ព្រោះថាគាត់ហ្នឹងមានព័ត៌មាន<បន្ថែម>ទាក់ទងទៅនឹងជនជាប់ចោទ។ ដូច្នេះដើម្បីឲ្យតុលាការអាចទទួលយកសក្ខីកម្មបន្ថែមនេះបាន <តុលាការចាំបាច់>ត្រូវតែ<>ស្តាប់សក្ខីកម្មរបស់គាត់ ដើម្បីផ្តល់<ឱកាស>ឲ្យមេធាវីការពារក្តី<មានប្រតិកម្មតបទៅនឹង

ទៅនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់គាត់ ពាក់ព័ន្ធនឹង>វត្តមានរបស់ជនជាប់ចោទទាំងពីររូបនោះនៅ<ការដ្ឋានមួយ ក្នុង>ឃុំលាយបូរ<ក្នុងឆ្នាំ១៩៧៧> ហើយលោកតុលាការមិនបានរឹតត្បិតវិសាលភាពនៃការចោទសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណីនេះទេ។ ដូច្នេះយើងមានសិទ្ធិប្រើពេលវេលាដែលយើងទទួលបាននេះ ទៅតាមចិត្តរបស់យើង។ ខ្ញុំចង់ឲ្យគាត់ឆ្លើយតបទៅនឹងព័ត៌មានដែលគាត់បានរៀបរាប់ទាក់ទងទៅនឹង ខៀវ សំផន ហើយនិង នួន ជា ហើយភាគីទាំងអស់ និងភាគីការពារក្ដីនោះនឹងមានលទ្ធភាពក្នុងចោទសំណួរទៅ<>ដើមបណ្ដឹងរដ្ឋប្បវេណី<លើប្រធានបទ>នេះ។ អ៊ីចឹងខ្ញុំមិនបានទទួលការបង្គាប់ណាពីអង្គជំនុំជម្រះ<ហាមឃាត់មិន>ឲ្យចោទសំណួរ<ទូទៅនោះទេ> គឺ<ខ្ញុំ>សួរសំណួរដែលពាក់ព័ន្ធ<នឹងផ្នែកនេះ ដែលអង្គជំនុំជម្រះត្រូវស្ដាប់ក្នុងសវនាការថ្ងៃនេះ>តែប៉ុណ្ណោះ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់បំពេញការងាររបស់ខ្ញុំតាមធម្មតា ចោទសំណួរពាក់ព័ន្ធ<> ទៅដើមបណ្ដឹងរដ្ឋប្បវេណី។ អ៊ីចឹងខ្ញុំមិនយល់ថាហេតុអ្វីយើងត្រូវរឹតត្បិតមក<>ត្រឹមទស្សនកិច្ចរបស់ថ្នាក់ដឹកនាំទាំងបួននាក់នេះ ពីព្រោះថាវិសាលភាពនៃសក្ខីកម្មរបស់គាត់នេះទូលាយជាងហ្នឹងទៀត លោកប្រធាន។

[០៩:៤៦:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ទី១ អង្គជំនុំជម្រះបានសម្រេចយល់ព្រមកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីនេះមកស្ដាប់សក្ខីកម្មរួចហើយ។ បញ្ហាទី២ ការសួរដេញដោលពិតមែនតែបញ្ជោចម្បងសារវន្តទៅលើវត្តមានដែលគាត់បានដឹងអំពីព័ត៌មានវត្តមាននៃការធ្វើទស្សនកិច្ចរបស់ថ្នាក់ដឹកនាំទៅនឹងសហករណ៍ត្រាំកក់ ប៉ុន្តែគ្រប់ដើមបណ្ដឹងរដ្ឋប្បវេណីសាក្សីទាំងអស់ ដែលដឹងអំពីព័ត៌មានពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការ ដូចជាសហករណ៍ត្រាំកក់ និងក្រាំងតាចាន់ គឺព័ត៌មានទាំងអស់នេះសុទ្ធតែអាចសួរបាន ឲ្យតែមានភាពពាក់ព័ន្ធជាមួយ ហើយសាក្សីដឹកពិតប្រាកដ។ ដូច្នេះគ្មានអ្វីត្រូវកែប្រែរបស់អង្គជំនុំជម្រះដែលកំណត់ស្ដាប់សក្ខីកម្មសាក្សីរូបនេះ អ៎! ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះឡើយ។

បាទ អង្គជំនុំជម្រះបដិសេធនូវការជំទាស់តវ៉ារបស់មេធាវីការពារក្ដី វ៉ិចទ័រ កូប៉េ ហើយលោកស្រីបន្តតាំងសំណួរទៀត ហើយលោកស្រីនិងសហព្រះរាជអាជ្ញាមានពេលវេលាពីត្រឹមនេះរហូតដល់ម៉ោងដប់ ដប់នាទី បានន័យថានៅសល់ប៉ុន្មាន មិនដល់២០នាទីទៀតទេ -- ២៣នាទី ២៥នាទីទៀតណ៎ះ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជិតចប់ហើយលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបញ្ចប់និយាយពីរឿង ជឹម ដែលជាអ្នកយាមនៅគុកអង្គតាសោម។ តើ ជឹម នេះគាត់មានបានផ្តល់ព័ត៌មានដោយផ្ទាល់អំពីជោគវាសនារបស់លោកប្តីលោកស្រីដែរឬទេ?

**លោក អ៊ុង សារឿន៖**

**ឆ៖** ចាស ជឹម ហ្នឹង គាត់ផ្តល់ ព្រោះគាត់នៅស្រុកកំណើតភូមិខ្ញុំដែរ ប៉ុនគាត់អ្នកទី១ ទ័ព។

**ស៖** តើ ជឹម នោះគាត់បានប្រាប់លោកស្រីនៅពេលណា នៅឆ្នាំណា លោកស្រីមានចាំខ្លះទេ?

**ឆ៖** គាត់ប្រាប់ពេល៧៩ ជួបគាត់ ចាប់គាត់ហ្នឹងមន្ទីរឃុំឃាំងនៅខេត្តតាកែវទៀត។ ដល់សព្វថ្ងៃ គាត់អត់ប៉ានចូលស្រុកផង ទៅនៅខេត្តបាត់ដំបង។ ឥឡូវគាត់ស្លាប់ហើយ អត់ប៉ានមកនៅស្រុកកំណើតផង។

[០៩:៤៩:៣៧]

**ស៖** សូមអរគុណលោកស្រី។ លោកស្រីបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខែមករា ឆ្នាំ២០១០ ខ្ញុំនៅមាននៅក្នុងដៃខ្ញុំនូវពាក្យសុំរបស់លោកស្រី គឺឯកសារ D22/2500។ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកស្រីសុំតាំងខ្លួនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី?

**ឆ៖** ចាស ខ្ញុំបានខ្ញុំចង់ដាក់ពាក្យបណ្តឹង ខ្ញុំ ស្លាប់បងប្អូន ប្តី កូន ឪពុកម្តាយ សាច់ញាតិ ទ្រព្យរបស់អីអស់ច្រើន។ ហើយខ្ញុំមកដាក់នេះ ខ្ញុំក៏អត់ដឹងអីដែរ ជិះឡានមកខ្លួនឯង។

**ស៖** នៅពេលដែលលោកស្រីនិយាយថាមកម្នាក់ឯង លោកស្រីចង់និយាយយ៉ាងម៉េចដែរ? ចង់មានន័យថាយ៉ាងម៉េច?

**ឆ៖** ចាស ខ្ញុំមកដាក់ពាក្យបណ្តឹងកន្លែងអង្គការហ្នឹង ខ្ញុំអត់ដឹងកន្លែងណាៗ ខ្ញុំអត់ស្គាល់ភ្នំពេញខ្ញុំជិះឡានមក ឡានឈ្នួលហ្នឹង គេថាស្គាល់កន្លែងអង្គការហ្នឹង ជូនខ្ញុំដាក់កន្លែងហ្នឹងទៅ។

**ស៖** សូមអរគុណ។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រីគឺឯកសារ D22/2500, ERN ជាភាសាខ្មែរនៅទំព័រ 00550905, ERNជាភាសាអង់គ្លេសគឺ 01069306 -- ខ្ញុំមើលទៅដូចជាពុំមានការបកប្រែជាភាសាបារាំងនៅឡើយទេ -- លោកស្រីបានឆ្លើយទាក់ទងទៅនឹងព្យសនកម្មផ្លូវចិត្ត។ ហើយអ៊ីចឹង ខ្ញុំសូមអានជាភាសាអង់គ្លេស ឃ្លាដែលលោកស្រីនិយាយ៖ "ខ្ញុំមានបញ្ហាផ្លូវចិត្ត តែខ្ញុំភ្លេចច្រើនណាស់"។ តើលោកស្រីមានបានធ្លាប់និយាយថាអ៊ីចឹងទេ? លោកស្រីមាន

បញ្ហាប្រសាទ ភ្លេចភ្លាំង ហើយលោកស្រីបាននិយាយពាក្យពេចន៍នេះនៅពេលណាដែរ?

[០៩:៥២:២៩]

**ឆ៖** ខ្ញុំ ចាសនាងខ្ញុំនិយាយកាលខ្ញុំមកដាក់ពាក្យ។ ខ្ញុំៗសម្រាន្តមិនលក់ ឈឺក្បាលរសេះរសោះ ហើយថប់ៗទ្រូង ខ្ញុំគិតឃើញរឿងហ្នឹងចេះតែរឿងថ្មី ខ្លួនខ្ញុំផ្ទាល់ហ្នឹង។ ហើយខ្ញុំដាក់ជាសសៃប្រសាទហ្នឹង ខ្លួនខ្ញុំទេ។

**ស៖** សូមអរគុណ។ លោកស្រីបានរៀបរាប់រឿងហេតុយ៉ាងច្បាស់លាស់នៅក្នុងសវនាការនេះ លោកស្រីបានឆ្លើយជាលាយលក្ខណ៍អក្សរផងដែរ។ <> អ៊ីចឹង ខ្ញុំសូមលោកស្រីថា នៅថ្ងៃនេះលោកស្រីមានអារម្មណ៍ថា លោកស្រីមានជំងឺភ្លេចភ្លាំង មានអារម្មណ៍ថាខ្លួនមានជំងឺភ្លេចភ្លាំង ឬក៏យ៉ាងណា? ហើយលោកស្រីចាំថា លោកស្រីបាននិយាយអ៊ីចឹងទេ ថាខ្លួនមានជំងឺភ្លេចភ្លាំង?

**ឆ៖** ចាស ខ្ញុំនិយាយ ប៉ុន្តែខ្ញុំចងចាំឥឡូវ ខ្ញុំអត់ភ្លេចភ្លាំងទេ អារម្មណ៍ខ្ញុំឥឡូវសម្រាន្តស្រួល។ ខ្ញុំបានថ្នាំពី ធី.ភី.អូ ម៉េច ខ្ញុំអត់សូវចងចាំ បើកថ្នាំហ្នឹង លេប អារម្មណ៍ខ្ញុំស្រួល ឥឡូវហ្នឹងស្រួល អត់មានភ្លេចភ្លាំងទេ នឹកឃើញរឿងដើម។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំសូមផ្តលវេទិកាទៅសហព្រះរាជអាជ្ញា។ សូមអរគុណច្រើន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ សូមអញ្ជើញសហព្រះរាជអាជ្ញា!

[០៩:៥៤:៤៥]

**លោក ស្រ៊ា រតនៈ៖**

សូមជម្រាបសួរអង្គសវនាការ។ សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំបាទឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** លោកស្រីបាន មុននេះលោកស្រីបានជម្រាបជូនអង្គសវនាការ អំពីរបបប្រហូបចុកនៅក្នុងសហករណ៍។ លោកស្រីបានលើកឡើងថារបបហូបចុកៗនោះគឺមានការខ្វះខាត។ ខ្ញុំចង់ជម្រាបសួរ

លោកស្រីបញ្ជាក់ថា តើនៅពេលដែលខ្វះខាតហ្នឹង លោកស្រីអាចមានសិទ្ធិតវ៉ា ឬសុំបន្ថែមអីបានទេ?

**លោកស្រី អ៊ុំង សារឿន៖**

**ឆ៖** ចាស អត់ទេ។ តវ៉ាត្រូវយកទៅសម្លាប់បាត់ ប៉ានតែសុំថែមគឺអត់បានហ្មង ឲ្យប៉ុន្នានគឺហូបប៉ុណ្ណឹង។ ចេះតែទ្រាំទៅហូបឆ្អែតមិនឆ្អែតចេះតែទ្រាំអ៊ីចឹងទៅ រកត្នោតទុំ រើសត្នោតទុំ គល់ចេក គល់ល្ហុងហ្នឹងចាស យកមកស្ងោរហូបទៅ លួចហូបទៀត ហ្នឹងលួចហូបអត់ឲ្យឃើញទេ។

**ស៖** ចុះលោកស្រីបានលើកឡើងអម្បាញ់មិញថា បើតវ៉ានឹងត្រូវៗបានគេយកទៅសម្លាប់។ ចុះលោកស្រីបានជួបអ្នកណាម្នាក់ដែលត្រូវបានគេសម្លាប់ដោយសារការតវ៉ារឿងខ្វះការហូបចុកនេះទេបាទ?

**ឆ៖** ចាសមាន តវ៉ាមាន។ ក្មេង អាយុប៉ុណ្ណឹង ១៥ឆ្នាំ តវ៉ាហូបមិនឆ្អែត លួចបាយសំណុំអ្នកសេដ្ឋកិច្ចទៅរកត្រី យកទៅហូបគេយកទៅសម្លាប់ឃើញ យកទៅសម្លាប់ហ្មង។

**ស៖** នៅពេលហ្នឹងលោកស្រីឃើញផ្ទាល់ភ្នែកមែនទេបាទ?

**ប្រធានអង្គជំនុំ៖**

សូមៗឆ្លើយលោកៗស្រី អ៊ុំង សារឿន អំមិញអត់ទាន់បានឆ្លើយទេ ឆ្លើយអំមិញអត់ -- ក្បាលមីក្រូហ្វូនអត់ប្រតិបត្តិការទេ។

**លោកស្រី អ៊ុំង សារឿន៖**

**ឆ៖** ចាស កាលហ្នឹងកុមារហ្នឹង អាយុ១៥ឆ្នាំ លួចបាយសំណុំខាងសេដ្ឋកិច្ចរកត្រីហ្នឹង យកទៅហូប ដល់ហើយគ្រូសិក្សា គេរាយការណ៍ទៅសិក្សា យកកុមារហ្នឹងទៅបាត់ សម្លាប់បាត់ហ្មង។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** តើក្នុងអំឡុងពេលដែលលោកស្រីរស់នៅក្នុងសហករណ៍នោះ លោកស្រីធ្លាប់ធ្លាក់ខ្លួនឈឺឬទេ?

**ឆ៖** ចាស នាងខ្ញុំឈឺៗស្រាប់តំណាងកងភូមិ គណៈកម្មការសេដ្ឋកិច្ចដាំបាយចុងភៅហ្នឹងថាដកបាយខ្ញុំ ថាខ្ញុំឈឺសតិអារម្មណ៍ ហើយកាលហ្នឹងខ្ញុំឈឺគ្រុនចាញ់ ឈឺចេញកើតថៃ កើតអីមកពីខ្វះខាតអីហ្នឹង ជំនាន់ហ្នឹង ៧៦ហ្នឹង ខ្ញុំឈឺៗខ្លាំង យកទៅខ្ញុំដាក់មន្ទីរពេទ្យឃុំលាយបូរហ្នឹង។ ពេទ្យហ្នឹងចែកជាមុខសញ្ញាទៀត ពេទ្យថា១៧ ឃុំលាយបូរ។

[០៩:៥៨:១៥]

**ស៖** នៅមន្ទីរពេទ្យហ្នឹងលោកស្រីទទួលបានការព្យាបាលយ៉ាងដូចម្ដេចដែរ?

**ឆ៖** ចាស យកខ្ញុំទៅដាក់សេរ៉ូម ឲ្យលេបថ្នាំៗគ្រាប់ដូចធ្វើជាដំឡូងមី ហើយសេរ៉ូមជាទឹកដូង យកស្រស់ យកទៅ យកដាក់ជើងខ្ញុំហ្នឹងខូច ដើរទៅខ្ទើកៗទល់សព្វថ្ងៃនៅឈឺដែរ ខ្ញុំនាងខ្ញុំបានតានោះ គាត់ប្រាប់ថា “តែទុកស្វិតជើងហើយ” គាត់ឲ្យរកអង្រ្កង ពន្លៃ ស្រា ឲ្យសុំមេស្រាយកមកស្អំរឹតទៅ។

**ស៖** ចុះសមាជិកសហករណ៍ផ្សេងទៀតមានអ្នកធ្លាក់ខ្លួនឈឺដែរទេ?

**ឆ៖** ចាស មាន។

**ស៖** ចុះវាសនាពួកគេនោះយ៉ាងដូចម្ដេចដែរ? សូមលោកស្រីរៀបរាប់តែអ្នកដែលលោកស្រីបានឃើញផ្ទាល់ភ្នែក។

**ឆ៖** ចាស នាងខ្ញុំឃើញផ្ទាល់ភ្នែក ឈឺ ជំងឺផ្សេងៗគ្នា។ ខ្លះឈឺខ្លាំងអ៊ីចឹងទៅជាៗស្លាប់ក៏មាន ខ្លះជាក៏មាន។

**ស៖** លើសពីនេះទៀត តាមរយៈឯកសារ E344.1, ERN (សុំទោស) ឯកសារ D22/2500a ជាភាសាខ្មែរ ERN 00587133 ដល់ 34 និងឯកសារមួយទៀតជាភាសាអង់គ្លេស D22/2500b, ERN ជាភាសាអង់គ្លេស 00594688 ដល់ 89 នៅក្នុងនោះលោកស្រីបានរៀបរាប់អំពីការផ្លាស់ប្ដូរសហករណ៍មួយទៅសហករណ៍មួយជាបន្តបន្ទាប់។ ប៉ុន្តែក្នុងស្ថានភាពជារួម គឺលោកស្រីលើកឡើងថា លោកស្រីឧស្សាហ៍ឃើញខ្មែរក្រហមយកមនុស្សទៅសម្លាប់ដោយផ្ទាល់ភ្នែក។ ខ្ញុំចង់ជម្រាបសួរលោកស្រីបញ្ជាក់ថា តើលោកស្រីដឹងពីមូលហេតុ ហេតុអីបានពួកគាត់ត្រូវបានគេនាំយកទៅសម្លាប់ទេ?

**ឆ៖** ចាស មូលហេតុគាត់ កងយុវជន គាត់ហូបមិនឆ្អែត គាត់លួចៗជាដំឡូង លួចជាពោត អំពៅ ដាំខ្លួនឯងហ្នឹង ឌីឡើក តែបាន គេយកទៅកសាង ឃើញបណ្ដើរទៅ ជួនណាក៏បានមកវិញ ជួនណា ក៏បាត់ទៅ។

**ស៖** លោកស្រីឃើញស្ថានភាពបែបនេះញឹកញាប់ទេ? បានន័យថាឃើញគេនាំមនុស្សយកទៅសម្លាប់ដោយផ្ទាល់ភ្នែកបែបហ្នឹងញឹកញាប់ទេ?

**ឆ៖** ចាស យូរៗឃើញម្ដង នាងខ្ញុំយូរៗឃើញម្ដង។

**ស៖** តើការនាំមនុស្សទៅសម្លាប់ហ្នឹងគេច្រើនធ្វើឡើងនៅពេលណា? ពេលថ្ងៃ ឬក៏យប់?

**ឆ៖** ចាស នាងខ្ញុំឃើញថ្ងៃ។ បើយប់នាងខ្ញុំអត់ដឹងទេ ឃើញតែពេលថ្ងៃ។

**លោក ស្រ៊ា រតនៈ៖**

បាទ សូមអរគុណលោកស្រី។ ខ្ញុំបាទអស់សំណួរហើយលោកប្រធាន។

[១០:០២:៣២]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំនៅសល់ពេលប្រហែលជា១០នាទីទេ។ ខ្ញុំសួរសំណួរមួយចំនួន ហើយខ្ញុំនឹងបញ្ចាំងសម្រង់វីដេអូមួយ។

**ស៖** សំណួរទីមួយ អម្បាញ់មិញលោកស្រីនិយាយអំពីការជម្លៀសចេញពីក្រុងតាកែវ ហើយលោកស្រីទៅដល់វត្តចំប៉ាលើ តើលោកស្រីអាចបញ្ជាក់បានទេ ថាមានមនុស្សច្រើនទេ ត្រូវបានគេជម្លៀសទៅវត្តចំប៉ាលើហ្នឹង?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស ប្រជាជនចេញពីក្នុងខេត្តតាកែវទៅច្រើនរាប់ម៉ឺន រាប់លាន ក្នុងខេត្ត ចេញទាំងអស់ជម្លៀសទៅទាំងអស់។

**ស៖** តើនៅក្នុងវត្តហ្នឹងគេមានធ្វើការស៊ើបអង្កេតថា តើមានអ្នកណាជាអ្នកមានបណ្ដាស័ក្តិនៅក្នុងរបបលន់នល់ ឬក៏ជាមន្ត្រីរដ្ឋការជាន់ខ្ពស់ទេ? លោកស្រីមានចាំទេ ថាខ្មែរក្រហមគេមានបានដើរស៊ើបមើលថាអ្នកណាជាទាហានលន់នល់ មានឬក៏អ្នកមានបណ្ដាស័ក្តិអីទេនៅពេលនុ៎ង?

**ឆ៖** ចាស នាងខ្ញុំចាំ។ គាត់មានដើរកត់ថា "មិត្តយើងធ្វើអី? ប្រាប់មក! ខ្ញុំរកការងារឲ្យធ្វើវិញ ចូលធ្វើកន្លែងដដែលវិញ"។ ហើយគាត់ចាញ់ប្រាជ្ញា អត់ដឹង ដូចនាងខ្ញុំក៏អត់ដឹងដែរ ប្រាប់ទៅ កត់ថ្ងៃក្រោយ ស្រង់ឈ្មោះហ្នឹងយកទៅបាត់ៗទៅ។

**ស៖** តើនៅក្នុងវត្តនោះមានមនុស្សបាត់ខ្លួនទេ? គឺថាបន្ទាប់ពីបានរៀបរាប់ថាខ្លួន ឧទាហរណ៍ថាខ្លួនជាកងទ័ព ឬជាយោធាអីចឹងទៅ បន្ទាប់មកតើមានការបាត់ខ្លួនទេ?

**ឆ៖** ចាស បាត់ មាខ្ញុំគាត់ធ្វើគិញ គ្រូ ប៉េអឹម ប៉ូលិស ទាហាន គយ យកទៅ ថាទៅធ្វើការបាត់រហូតទល់សព្វថ្ងៃ។

[១០:០៥:០៩]

**ស៖** សូមអរគុណ។ ពាក់ព័ន្ធនឹងការបាត់ខ្លួនដដែលនេះ អម្បាញ់មិញនេះលោកស្រីនិយាយថា ប្ដីរបស់លោកស្រីប្រហែលជាបញ្ជូនពីអង្គតាសោមទៅក្រាំងតាចាន់។ ហើយនៅក្នុងឯកសារ D22/

2500 លោកស្រីបញ្ជាក់ថា នៅឆ្នាំ៧៨ បង<ប្អូនប្រុស>របស់លោកស្រី អ៊ុង លីម ហ្នឹងត្រូវបានគេសម្លាប់នៅក្រាំងតាចាន់។ តើត្រឹមត្រូវទេ? <ប្រសិនបើអ៊ីចឹងមែន តើលោកស្រីដឹងដោយរបៀបណាថាបងប្អូនប្រុស>របស់លោកស្រី អ៊ុង លីម ហ្នឹងត្រូវបានគេសម្លាប់នៅទីនោះ?

**ឆ៖** ចាស បងខ្ញុំ អ៊ុង លីម គាត់រកសេដ្ឋកិច្ច ដល់ពេលរកបានអ៊ីចឹងទៅគាត់អ្នក១៧ គាត់ដូចថាគាត់ស្គាល់អ៊ីចឹង គាត់សុំឲ្យបារីមួយ ដល់ថ្ងៃក្រោយឡើង គេកសាងបងខ្ញុំ ស្រាប់យកទៅបាត់ទៅ។

**ស៖** លោកស្រីក៏បានឆ្លើយផងដែរថា ឪពុករបស់លោក<ស្រី ឈ្មោះ អ៊ុម ពុម្ព> ហើយនិងពូ<ឈ្មោះ អ៊ុម ចក>ត្រូវបានគេនាំយកទៅសម្លាប់នៅក្រាំងតាចាន់នៅឆ្នាំ១៩៧៦។ តើលោកស្រីដឹងយ៉ាងម៉េចថា បង<ប្រុស>របស់លោកស្រី<ឈ្មោះ អ៊ុង លីម ហើយបន្ទាប់មកគឺ>ឪពុករបស់លោកស្រី និងពូរបស់លោកស្រីហ្នឹងត្រូវបាននាំយកទៅសម្លាប់នៅក្រាំងតាចាន់នោះ?

**ឆ៖** ចាស មានឯកសារនៅក្រាំងតាចាន់ ហើយទ័ព -- កងទ័ពប៉ុល ពត ហ្នឹងយកមកដាក់ហ្នឹង គាត់រាយការណ៍ប្រាប់ ពូជឹម ហ្នឹងគាត់ប្រាប់ថា ឈ្មោះនៅលើគាត់។ ហើយដាក់ឈ្មោះនៅមន្ទីរឃុំឃាំងនៅក្រាំងតាចាន់ មានទៀត។

[១០:០៧:២៣]

**ស៖** នៅពេលដែលលោកស្រីនៅលាយបូរ គឺលោកស្រីនៅសហករណ៍<ក៣> តើលោកស្រីមានឃើញសហករណ៍គំរូ ដែលគេហៅថា “<ក១>” ទេ? <តើលោកស្រីមានឃើញអគារ នៃក១ ដែរឬទេ?>

**ឆ៖** ចាស នាងខ្ញុំឃើញ នាងខ្ញុំស្គាល់ នៅពីខាងត្បូងភូមិនាងខ្ញុំនៅ។ ខ្ញុំអ្នក១៧ ដាក់ពីខាងជើងកណ្តាលដាក់កង២, កង១នៅពីខាងត្បូងជិតសាលាឃុំ។ មន្ទីរពេទ្យក៏ខុសគ្នាដែរ សហករណ៍បាយក៏ខុសគ្នាដែរ។

**ស៖** តើកងរបស់អ្នកមូលដ្ឋានដែលជាសហករណ៍<>គំរូ <“ក១”> ហ្នឹង គេមានហៅថា “កងមហាអស្ចារ្យ មហាលោតផ្លោះ” ទេ?

**ឆ៖** ចាស ហៅ។ គ្រាន់តែជាគំរូឲ្យមើល មិត្តយើងជាគំរូ។

**ស៖** ហេតុអ្វីបានជាគេហៅកងហ្នឹងថាជា “កងគំរូ កងមហាអស្ចារ្យ មហាលោតផ្លោះ”នោះ តើកងហ្នឹងវាខុសពីកងផ្សេងៗទៀតយ៉ាងម៉េចដែរ?

**ឆ៖** ចាស គាត់អត់ពាក់ព័ន្ធអ្នក១៧មេសា គាត់ល្អ។

**ស៖** តើលោកស្រីមានធ្វើការជាមួយលោកស្រី <ជូ គឹមឡន> ទេ? លោកស្រីស្គាល់គាត់ទេនៅពេលដែលលោកស្រីនៅធ្វើការនៅលាយបូរហ្នឹង?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាល់ទានឆ្លើយតប។ សូមអញ្ជើញលោក វីរទ័រ កូប៉េ!

[១០:០៩:៣៩]

**លោក វីចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏កត់សម្គាល់ឃើញថាសហព្រះរាជអាជ្ញាមិនមានចំណាប់អារម្មណ៍ទាក់ទងទៅនឹងការធ្វើទស្សនកិច្ចរបស់មេដឹកនាំជាន់ខ្ពស់នោះទេ។ ខ្ញុំ<ចង់និយាយ>ថា<យើងនឹងមានការភាន់ច្រឡំចំពោះសំណើនេះ>។ <នេះជាពេលចុងក្រោយ ដែលយើងយល់ព្រមលើសំណើឱ្យ>ដើមបណ្ដឹងរដ្ឋប្បវេណី<មកផ្ដល់សក្ខីកម្មនៅទីនេះ។ បើសិនយើងមិន>មានហេតុផលច្បាស់លាស់ដែលភាគីទាំងពីរមិនបានយកចិត្តទុកដាក់ផ្ដោតទៅលើប្រធានបទ<>ដែលត្រូវតាំងសំណួរនោះទេ បើដូច្នេះទេ គឺថាយើងខាតបង់ពេលវេលានៃការសួរសក្ខីកម្មក្នុងរយៈពេលមួយថ្ងៃ។ សហព្រះរាជអាជ្ញាមាន១០នាទី តែប៉ុណ្ណោះ។ <គាត់មិនសួរសំណួរសូម្បីតែមួយដែលពាក់ព័ន្ធនឹងប្រធានបទនេះទេ។>

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធានខ្ញុំសូមឆ្លើយតប។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ ខ្ញុំសូមជំទាស់ចំពោះសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងការបញ្ជាក់ឈ្មោះទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ហើយដែលកន្លងមក ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមិនទាន់បាននិយាយអំពីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ទៀតដែលលើកឡើងដោយសហព្រះរាជអាជ្ញាអម្បាញ់ មិញនេះទេ។ បើដូច្នេះ ការសួរបែបនេះ វាជាការសួរនាំមុខដើម្បីឱ្យដើមបណ្ដឹរដ្ឋប្បវេណីគ្រាន់តែឆ្លើយបញ្ជាក់តែប៉ុណ្ណោះ។ បាទ សូមអរគុណ។

[១០:១១:១៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន គេកំពុងតែរារាំងខ្ញុំមិនឱ្យសួរឱ្យចប់តាមពេលហើយ។ ខ្ញុំ<>សូមសួរតែសំណួរពីរទៀតដើម្បីបញ្ចប់ហើយ និងបង្ហាញវីដេអូ<ដែលមានរយៈពេល៤០វិនាទី>។ សហព្រះរាជអាជ្ញាជាអ្នកសម្រេចថាគាត់ចង់សួរអីមិនមែនមេធាវីការពារក្ដី<ជាអ្នកសម្រេច>ថាឱ្យ<សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីត្រូវផ្ដល់សក្ខីកម្ម>យ៉ាងម៉េចៗនោះទេ។ គឺអង្គជំនុំជម្រះជាអ្នកសម្រេច។ លោកខាងមេធាវីការពារក្ដីលោកមានពេលសួរ អ៊ីចឹងពេលលោកសួរៗទៅទាក់ទងរឿងទស្សនកិច្ចនោះ។ ចំពោះយើង គឺយើងសួរតាម<ឯកសារដែលយើងទទួលបាន និងវាច្បាស់លាស់ដោយមិនចាំបាច់មានការបកស្រាយថែមទៀតទេ>។ ខ្ញុំ -- ចំពោះការដែលខ្ញុំលើកឡើងឈ្មោះនោះមិនមែនជាសំណួរនាំមុខទេ។ ខ្ញុំគ្រាន់តែសួរចង់ដឹងថាតើគាត់ៗធ្លាប់ធ្វើការជាមួយលោក ជូ គឹមឡន ឬក៏អត់ នៅជាមួយក្នុងកងជាមួយគ្នាអត់? ដូច្នេះ<ការដែលមិននិយាយឈ្មោះនេះពីមុន> មិនមែន<មានន័យថា> សំណួរនេះ<>ជាសំណួរនាំមុខទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីទាំងពីរក្រុម ហើយដោយសំណួរនេះ ជាសំណួរសមស្របដែលអង្គជំនុំជម្រះត្រូវការស្ដាប់ចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។

លោកស្រី អ៊ុំង សារឿន អាចឆ្លើយតបសំណួរដែលសួរចុងក្រោយដោយសហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំសូមសួរឡើងវិញ។ តើលោកស្រីមានធ្វើការជាមួយលោកស្រី ជូ គឹមឡន <ក្នុងកងតែមួយ>នៅលាយបូរទេ? ជាពិសេសនៅពេលដែលមេដឹកនាំមកមើលការដ្ឋាននោះ លោកស្រីមានធ្វើការនៅក្នុងក្រុមតែមួយជាមួយលោកស្រី ជូ គឹមឡន ទេ?

[១០:១២:៥៩]

**លោកស្រី អ៊ុំង សារឿន៖**

**ឆ៖** ចាស នាងខ្ញុំក្រុមផ្សេង ប៉ុន្តែ ជូ គឹមឡាន គាត់ក្រុមផ្សេងនៅជិតគ្នា ថ្ងៃតែមួយហ្នឹង។

**ស៖** កាលពីថ្ងៃទី២៧ មករា ឆ្នាំ២០១៥ នៅម៉ោង១៤:០៣នាទី ជូ គឹមឡន និយាយថា “តានួវជាអ្នកទទួលបន្ទុកបញ្ជាឃោធានៅឃុំលាយបូរ” ហើយនៅម៉ោង ១៤:០៥នាទី ជូ គឹមឡន បាននិយាយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថា "ម្នាក់ៗខ្លាចតានូវណាស់ នៅពេលដែលឃើញ តានូវ ម្នាក់ៗគឺខំធ្វើការណាស់ ពីព្រោះតានូវ នេះតឹងរ៉ឹងណាស់"។ អ៊ីចឹងខ្ញុំចង់ដឹងថា លោកស្រីផ្ទាល់នោះ លោកស្រីខ្លាច តានូវ ទេនៅសម័យនោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមជំទាស់ពាក់ព័ន្ធទៅនឹងសំណួរនេះ។ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានឆ្លើយហើយ គេសួរគាត់ពាក់ព័ន្ធទៅនឹង តានូវ <និងអត្តចរិតរបស់គាត់>។ អ៊ីចឹងការសួរអ៊ីចឹង គឺសួរដដែល <ហើយជាសំណួរនាំមុខ ពីព្រោះសហព្រះរាជអាជ្ញាព្យាយាមរៀបសំណួរដោយលើកឡើងពីឈ្មោះអ្នកធ្វើការជាមួយដើមបណ្ដឹងរដ្ឋប្បវេណី>។ សួរអ៊ីចឹងគឺថាមិនត្រឹមត្រូវទេ ហើយពីប៉ុន្មាន<នាទី>មុននេះ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់ឆ្លើយថា គាត់មិនអាចឆ្លើយអីក្រៅពី<អត្តចរិតរបស់គាត់>ហ្នឹងបានទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ដើម្បីចំណេញពេលវេលា ខ្ញុំសួរឡើងវិញ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** អម្បាញ់មិញនេះ លោកស្រីនិយាយអំពី តានូវ ហើយលោកស្រីថា<តានូវ ឱ្យ>គេមកយកពូរបស់លោកស្រីទៅ<> ហើយបន្ទាប់មកពូលោកស្រីគេវ៉ៃបាក់ធ្មេញអស់រលីង។ អ៊ីចឹងលោកស្រីអាចបញ្ជាក់បានទេថា មនុស្សគ្រប់គ្នានៅឃុំលាយបូរហ្នឹងខ្លាច តានូវ ណាស់?

**ឆ៖** ចាស នាងខ្ញុំខ្លាច គាត់ជាមេឃុំខ្លាចគាត់ មុខគាត់កាច ខ្ញុំខ្លាច។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអរគុណ ហើយអស់ពេលហើយ។

ហើយដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សឹមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី សួរទៅអស់លោក លោកស្រីចៅក្រមតើមានសំណួរអ្វីចង់សួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ។ អញ្ជើញលោកស្រី ក្លូឌា ហ្វេនស៍។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អរគុណលោកប្រធាន។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** លោកស្រីសាក្សី ខ្ញុំចង់សួរលោកស្រីអំពីដំណើរទស្សនកិច្ចរបស់មេដឹកនាំនៅការដ្ឋានការងាររបស់លោកស្រី។ មុននឹងខ្ញុំតាំងសំណួរ យើងខ្ញុំដឹងថារយៈពេលគឺ ជិត<>៤០ឆ្នាំមកហើយ ពាក់ព័ន្ធទៅនឹងព្រឹត្តិហេតុទាំងអស់នេះ។ ប្រសិនណាជាលោកស្រីមិនចាំទេ សូមលោកស្រីគ្រាន់តែឆ្លើយថា ខ្ញុំអត់ចាំទេ។ លោកស្រីយល់ទេ លោកស្រី?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស។

**ស៖** ដូច្នេះ ត្រឡប់ទៅនិយាយអំពីដំណើរទស្សនកិច្ចរបស់មេដឹកនាំ លោកស្រីជម្រាបជូនតុលាការថាមេដឹកនាំនេះគឺថាបានជិះឡានទៅទីនោះ ហើយមានមនុស្សជាច្រើននៅទីនោះ។ ហើយ <យឿន> គឺថាបានចង្អុលបង្ហាញទៅលោកស្រីថា មេដឹកនាំទាំងបីហ្នឹងគឺមាន ប៉ុល ពត, នួន ជា និង ខៀវ សំផន។ តើត្រូវដែរទេ?

**ឆ៖** ចាស ត្រូវ។

[១០:៣៣:៤៥]

**ស៖** ឥឡូវនេះខ្ញុំចង់ដឹងពេលដែលគេចង្អុលបង្ហាញមេដឹកនាំហ្នឹងប្រាប់លោកស្រីហ្នឹង តើនៅពេលដែលមេដឹកនាំនៅទីហ្នឹងតែម្តង ឬក៏មុនហ្នឹង ឬក៏ក្រោយពេលចាកចេញហើយ ទើបគេប្រាប់លោកស្រី?

**ឆ៖** ពីមុនហ្នឹង គាត់ប្រាប់ខ្ញុំថាអង្គការមក។ ដល់ពេលក្រោយ ថ្ងៃនុំងឃើញមកមែន។ ប៉ុន្តែពេលគាត់អញ្ជើញត្រឡប់ទៅវិញ បានគាត់ប្រាប់នាងខ្ញុំឈ្មោះ ខ្សឹបប្រាប់ទេ អត់ប្រាប់ឮទេ។

**ស៖** ឥឡូវខ្ញុំសូមសួរបញ្ជាក់អំពីឃ្លាចុងក្រោយ។ នៅពេលដែល <យឿន> និយាយថា ខៀវ សំផន, នួន ជា និង ប៉ុល ពត គឺថា<នៅ>ទីនេះ។ គឺនៅពេលហ្នឹង គឺពួកគាត់ចាកចេញទៅហើយ ឬក៏ពួកគាត់នៅទីនោះនៅឡើយ?

**ឆ៖** ចាស គាត់ចេញទៅបាត់ហើយ។

[១០:៣៥:០៥]

**ស៖** ខ្ញុំយល់ហើយ។ ដូច្នេះ គឺតាមពិតទៅ លោកស្រីមិនដឹងថាមេដឹកនាំដែលៗទៅទីនោះហ្នឹង គឺថាខ្លួនលោកស្រីផ្ទាល់ មិនដឹងថាជា ខៀវ សំផន, នួន ជា <>ទេ គឺដោយសារតែគេប្រាប់នោះទេទើបលោកស្រីដឹង។ តើ<>អ៊ីចឹងមែនទេ?

**ឆ៖** ចាស ពិតមែន ខ្ញុំអត់ស្គាល់។ ខ្ញុំស្គាល់តែ តាម៉ុក ហើយ តាសាន ហើយ តានូវ។

**ស៖** ដូច្នេះ លោកស្រីមិនអាច<មើលចំមុខ>ស្គាល់ឈ្មោះថាជាណាអ្នកណាឲ្យបានច្បាស់លាស់ទេ។ មែនទេ?

**ឆ៖** ចាស នាងខ្ញុំអត់ស្គាល់ទេ តាៗបីហ្នឹង អត់ -- ឃើញតែមួយភ្លែត អត់ការចងចាំ។

**ស៖** សូមលោកស្រីជម្រាបជូនតុលាការនៅពេលដែលគេប្រាប់លោកស្រី ឬនៅពេលដែលមេដឹកនាំទាំងបីហ្នឹង ត្រូវបានគេប្រាប់ឲ្យលោកស្រីបានស្គាល់ហ្នឹង តើលោកស្រីនៅទីណាហ្នឹង? ឬលោកស្រីនៅកន្លែងការដ្ឋានការងារដែលគេទៅពិនិត្យហ្នឹង ឬក៏លោកស្រីនៅកន្លែងផ្សេងទេ?

[១០:៣៦:២៤]

**ឆ៖** ចាស នាងខ្ញុំនៅការងារនៅកន្លែងកងចល័តហ្នឹង កន្លែងស្ពានីយរទេះភ្លើងហ្នឹង អូរចំបក់កងចល័តហ្នឹង។

**ស៖** ហើយតើលោកស្រីនៅៗពេល <យឿន> ប្រាប់ទៅលោកស្រីថា មេដឹកនាំដែលទើបចាក

ចេញ ឬក៏មេដឹកនាំក្នុងចំណោមដែលចាកចេញទៅហ្នឹង គឺមាន ខៀវ សំផន, នួន ជា និង ប៉ុល ពត។ លោកស្រីនៅកន្លែងការដ្ឋានការងារដដែលហ្នឹងទេ មែនទេ?

**ឆ៖** ចាស ខ្ញុំនៅធ្វើការកន្លែងហ្នឹងដដែល មិនទាន់ដល់ម៉ោងសម្រាក។

**ស៖** តើលោកស្រី នៅចម្ងាយប៉ុន្មានពីកន្លែងលោកស្រីធ្វើការ ទៅកន្លែងមេដឹកនាំនុ៎ង?

**ឆ៖** ចាស នាងខ្ញុំឃើញគាត់ហ្នឹង នៅចម្ងាយខាងស្ដាំដៃហ្នឹង ខាងជា -- ចំនួនជា ៥-៦ម៉ែត្រពីនុ៎ង ជិតថ្នល់ជាតិហ្នឹង ខ្ញុំនៅខាងក្រោម គាត់នៅលើថ្នល់ជាតិហ្នឹង។

**ស៖** នៅពេលហ្នឹង លោកស្រី<គ្រាន់មើលឃើញពីកន្លែង>ធ្វើការ ឬក៏គេឲ្យលោកស្រីទៅឈរហ្នឹង ដើម្បីស្វាគមន៍មេដឹកនាំហ្នឹង?

[១០:៣៨:០៧]

**ឆ៖** ចាស អត់ទេ ខ្ញុំនៅរែកដី បង្គីលើស្មា ទៅដឹក -- ទៅទទួលឯណា ខ្ញុំ១៧ ខំធ្វើឲ្យហើយ ខំសម្រុកឲ្យខ្លាំង។

**ស៖** លោកស្រីបានឃើញមេដឹកនាំហ្នឹងរយៈពេលប៉ុន្មានដែរ? ពីរបី<វិ>នាទី ឬក៏ពីរបី<នាទី ឬក៏កន្លះ>ម៉ោង រយៈពេលប៉ុន្មានដែរ លោកស្រី?

**ឆ៖** ចាស រយៈពេលខ្លី អត់ដល់ម៉ោងទេ។ អត់ដឹងប៉ុន្មាននាទី ព្រោះខ្ញុំអត់ៗដឹង ឆាប់ដែរ។

**ស៖** មកដល់ថ្ងៃនេះ <គឺរយៈពេល៤០ឆ្នាំហើយ> តើលោកស្រីនៅចាំមុខមេដឹកនាំដែលទៅធ្វើទស្សនកិច្ច ដែលទៅពិនិត្យកន្លែងការដ្ឋានការងារហ្នឹងទេ? លោកស្រីនៅចាំមុខមេដឹកនាំទាំងបីហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំអត់ចាំទេ ខ្ញុំចាំតែតាៗ ឃើញញឹកញាប់តែពីរនាក់ តែតាម៉ុក ហើយតាសានហើយ តានួវ, តាហួញ អីហ្នឹង ខ្ញុំចាំ ចងចាំ ឃើញញឹក។

**ស៖** ថ្ងៃនេះ បើសិនណាជាតុលាការបង្ហាញរូបថតមេដឹកនាំដែលទៅពិនិត្យកន្លែងការដ្ឋានការងារ តើលោកស្រីអាចចង្អុលបង្ហាញថា "នេះ មុខម្នាក់ -- មុខមេដឹកនាំម្នាក់នេះ មុខមេនាំម្នាក់នេះ គឺថាបានទៅធ្វើទស្សនកិច្ចនៅកន្លែងហ្នឹង លើកលែងតែ តាម៉ុក ហើយនិង តាសាន។ តើលោកស្រីអាចចង្អុលបង្ហាញបានទេ?

**ឆ៖** ចាស ខ្ញុំអត់ចាំ។

**ស៖** ហើយនេះជាសំណួរចុងក្រោយរបស់ខ្ញុំ លោកស្រីបានស្គាល់តាម៉ុកយ៉ាងច្បាស់ ហេតុអ្វីបានជាលោកស្រីស្គាល់ តាម៉ុក ច្បាស់ម្ល៉េះ?

[១០:៤០:២២]

**ឆ៖** ចាស នាងខ្ញុំនៅធ្វើការហ្នឹង។ តាម៉ុក គាត់នៅផ្ទះនៅលើទឹកហ្នឹង ពីខាងកើតអូរចំបក់ ហើយគាត់ឧស្សាហ៍ចេញចូលមកផ្លូវជាតិហ្នឹង ឡានគាត់។ ជួនណាគាត់ជិះមកម្នាក់ឯង ជួនណាមាននីរសារ។ ខ្ញុំស្គាល់ជាក់តាម៉ុក។ យ៉ាងយូរមួយអាទិត្យ ហើយនិង១០ថ្ងៃគាត់ចុះមកធ្វើការ មកធ្វើ មកមើលម្ដងហើយ។

**ចៅក្រម ក្ដួឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

លោកប្រធាន ខ្ញុំសូមធ្វើការអនុញ្ញាតបញ្ចាំងវីដេអូមួយដែលមានលេខ<E3/3091R>

**អ្នកបកប្រែ៖**

លោកប្រធាន ឮសំឡេងរំខានពិបាកណាស់លោកប្រធាន ពីអ្នកបកប្រែ។

**ប្រធានអង្គជំនុំ៖**

លោក១ៗ មានបញ្ហាបកប្រែភាសា វាខ្ទ័រ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងខាងបច្ចេកទេសសំឡេង។

*(មានបញ្ហាបច្ចេកទេស)*

[១០:៤១:៥៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញចាប់ផ្ដើមឡើងសាជាថ្មីឡើងវិញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធានខ្ញុំសូមធ្វើការអនុញ្ញាតបញ្ចាំងវីដេអូមួយ ដែលមានលេខ E3/3091R គឺដែលមានលេខយោង V00172427 គឺចាប់ពីម៉ោងសែសិបបីនាទី ដប់បីវិនាទី ទៅដល់សែសិបបីនាទី ហាសិបប្រាំពីរវិនាទី។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតបញ្ចាំងវីដេអូនេះ ដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមើលថាតើ

គាត់ស្គាល់អ្នកណាទេ នៅក្នុងវីដេអូនេះ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះ -- យើងអនុញ្ញាត ហើយបង្គាប់ឱ្យខាង អាយ.ធី ចាក់ផ្សាយវីដេអូតាមសំណើសុំរបស់លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ អម្បាញ់មិញនេះ។

*(ការបង្ហាញឯកសារជារូបភាព)*

[១០:៤៤:១២]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកស្រី តើលោកមានស្គាល់អ្នកណាខ្លះទេនៅក្នុងវីដេអូដែលយើងចាក់ឱ្យមើលអម្បាញ់មិញនេះ?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស ខ្ញុំឃើញតាសាន។ ខ្ញុំស្គាល់តាសាន។

**ស៖** ចុះអ្នកផ្សេងទៀតក្រៅពីតាសាន លោកស្រីមានស្គាល់អ្នកណាទៀតទេ?

**ឆ៖** ចាស អត់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធានដើម្បីកុំឱ្យស្រពិចស្រពិល សូមចាក់វីដេអូនេះម្តងទៀត។ ហើយសូមឱ្យគាត់បញ្ជាក់ឱ្យច្បាស់ថា តាសានហ្នឹងរូបមួយណា ឱ្យគាត់ចង្អុលបង្ហាញ។

**ប្រធានអង្គជំនុំ៖**

បាទ បុគ្គលិក អាយ.ធី ចាក់ផ្សាយវីដេអូ អម្បាញ់មិញនេះសាជាថ្មីម្តងទៀត!

[១០:៤៦:៣០]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី អ្វីដែលខ្ញុំចង់ធ្វើនេះគឺថា នៅពេលដែលចាក់ឡើងវិញនេះគឺខ្ញុំចង់ឱ្យលោកស្រីបញ្ជាក់ថា មួយណាជា តាសាន ហ្នឹង? សូមលោកស្រីចង្អុលបញ្ជាក់តែម្តងថា ពេលរូបហ្នឹងទៅលោកស្រីអាចបញ្ជាក់ថា "អូ៎! នេះហើយ តាសាន"។ តើលោកស្រីយល់ទេ ជាភាសាខ្មែរ ខ្ញុំនិយាយទៅយល់ទេ?

**ឆ៖** ចាស យល់។

**ស៖** អ៊ីចឹងនៅលើវីដេអូហ្នឹង គឺលោកស្រីស្គាល់ តាសាន ឬក៏មិនស្គាល់ទេ?

**ឆ៖** ចាស ខ្ញុំស្គាល់។ គាត់ ខ្ញុំចំណាំគាត់ឧស្សាហ៍ចេញចូល ព្រោះគាត់មានសាច់ញាតិនៅភូមិខ្ញុំពីរល្វែង។ ឥឡូវគាត់ដូរត្រកូលទៀត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី យើងនឹងចាក់ម្ដងទៀតនៅពេលដែល<លោកស្រីមើល> ឃើញថា រូបតាសាន នេះហើយៗ <សូមនិយាយ>ថាឈប់ៗ<>!។ លោកស្រីយល់ទេ?

**ប្រធានអង្គជំនុំ៖**

បាទ ផ្នែក អាយ.ធី ចាក់ផ្សាយវីដេអូអំមិញម្ដងទៀត ហើយនៅពេលណាដែលឃើញដើមបណ្ដឹងរដ្ឋប្បវេណីគាត់និយាយថា ឲ្យឈប់ គឺស្តុប ត្រឹមហ្នឹងដើម្បីឲ្យគាត់ពិនិត្យមើលលើរូបភាពដែលគាត់ថាស្គាល់ឈ្មោះ សាន នោះ។

**លោកស្រី អ៊ុង សារឿន៖**

នេះ តាសាន! ព្រះកេសគាត់រាងល្វៀលៗ ឥឡូវ -- គាត់កាលមុនក្មេង ឥឡូវគាត់ចាស់ហើយ។

[១០:៤៩:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អាចផ្អាច់បានហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

នៅពេលដែលឃើញ តាសាន គឺឲ្យគាត់បានលើកដៃ ប៉ុន្តែវីដេអូ ហ្នឹងឈប់នៅពេលក្រោយ។ ដូច្នេះ ខ្ញុំឃើញថា <លោកស្រីដូចជាបានបង្ហាញថាស្គាល់រូបនេះ។> ក៏ប៉ុន្តែនៅពេលដែលគាត់លើកដៃចង្អុលហ្នឹង វីដេអូនៅតែទៅមុខទៀត ប្រហែលជាគ្រាន់តែឲ្យគាត់លើកដៃទៅពេលដល់ តាសាន គ្រាន់តែលើកដៃទៅបានហើយ ហើយយើងទាំងអស់នឹង<មើលថាតើគាត់ស្គាល់រូបក្នុងវីដេអូនេះឬក៏អត់>។

[១០:៥០:៥២]

**ប្រធានអង្គជំនុំ៖**

អាយ.ធី ចាក់ផ្សាយម្ដងទៀត។ ហើយម្ដងនេះគឺប្ដូរវិធីសាស្ត្រម្ដង ចាំស្ដាប់លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ឲ្យឈប់ សូមលោកឈប់ ស្តុបនូវការបញ្ចាវីឌីអូហ្នឹងឲ្យឈប់ដើម្បីសួរបញ្ជាក់ទៅដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក វិុចទ័រ កូប៉េ៖**

ខ្ញុំដឹងថាគាត់ស្គាល់ តាសាន ការធ្វើបែបនេះ មិនៗៗគួរធ្វើបែបនេះទេ បើដូច្នេះគឺជាការនាំមុខសាក្សីហើយ។ <ដោយសារពេលនេះ វាមិនទាក់ទងគ្នា> ប៉ុន្តែលើកក្រោយនេះ សូមមេត្តាធ្វើម៉េចកុំឲ្យធ្វើចូលទៅក្នុងលក្ខណៈមួយគេហៅថានាំមុខទៅដល់សាក្សី។ <ឥឡូវនេះ ខ្ញុំមិនមានបញ្ហាអ្វីនោះទេ ពីព្រោះខ្ញុំដឹងថាសាក្សីស្គាល់ តាសាន ហើយ។>

**<ចៅក្រម ក្ខុឌា ហ្វេនស៍៖>**

<ប៉ុន្តែដំណើរការនេះគឺស្ថិតនៅក្នុងកំណត់ត្រា។>

**<លោក វិុចទ័រ កូប៉េ៖>**

<ត្រឹមត្រូវ។>

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំអត់យល់អម្បាញ់មិញ លោកថាការបញ្ចាំងហ្នឹងនាំមុខយ៉ាងម៉េចខ្ញុំអត់យល់ទេ <>ខ្ញុំមិនបាននាំមុខសាក្សីអីទេ។ សូមលោកបញ្ជាក់ឡើងវិញទៅមើល៍?

**លោក វិុចទ័រ កូប៉េ៖**

ឥឡូវនេះ បើសិនណាយើងឈប់ចំរូប តាសាន ហើយសួរថាតើនេះគឺជាបុគ្គលហ្នឹងឬអត់? នេះគឺជាសំណួរនាំមុខហើយ គ្រាន់តែឲ្យតែចាក់វីឌីអូទៅ ហើយពេលគាត់លើកដៃទៅ<នៅពេលដែលគាត់ឃើញរូបហ្នឹងបានហើយ> យើងអាច<មើល>នឹងដឹងទាំងអស់គ្នាហើយ <ការធ្វើបែបនេះគឺត្រឹមត្រូវបំផុត>។ <នៅក្នុងពេលនេះ> ការធ្វើយ៉ាងម៉េចក៏គាត់នៅតែអាចស្គាល់បានដែរ ខ្ញុំមិនជំទាស់អីទេ ប៉ុន្តែៗកុំឲ្យនាំមុខ។

[១០:៥២:៥០]

**ប្រធានអង្គជំនុំ៖**

បញ្ហានៅត្រង់ថាពេលដែលគាត់លើកដៃ ពេលដល់រូបហ្នឹងហើយ ទម្រាំតែស្ទុប អារូបហ្នឹងវាហួសបាត់ហើយ ព្រោះវីឌីអូវាទៅ វិលទៅមុខលឿន។ បានចប់ត្រឹមហ្នឹងទៅ ហើយព្រោះមេធាវីគាត់មិនតវ៉ាអីទេបញ្ហាហ្នឹង គ្រាន់ជាការកត់សម្គាល់ប៉ុណ្ណោះ។

លោកចៅក្រមមានសំណួរអីសួរពាក់ព័ន្ធជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីនេះទៀតទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីឲ្យច្បាស់ទាំងអស់គ្នា<ថាសាក្សីស្គាល់រូបហ្នឹង> ខ្ញុំគិតថាបង្ហាញរូបហ្នឹង<ម្ដងទៀត> ហើយសួរគាត់ថាគាត់ស្គាល់ឬអត់ ដូចជាអត់មានបញ្ហាអីទេ យើងសូមបន្តចាក់ឡើងវិញ ហើយនៅពេលដែលខ្ញុំប្រាប់ថា "ស្តុប" គឺយើងស្តុបទៅ ហើយខ្ញុំនឹងសួរគាត់ ថាតើម្នាក់ហ្នឹងមែនទេ តាសាន ហ្នឹង?

[១០:៥៤:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អាយ.ធី ចាក់ម្ដងទៀត ហើយធ្វើតាមការណែនាំរបស់ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ចុះ!

*(ការបង្ហាញឯកសារជាវីដេអូ-រូបភាព)*

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

**ស៖** ស្តុបៗ! លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីស្គាល់រូបហ្នឹងទេ?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស ខ្ញុំស្គាល់។

**ស៖** យើងឃើញរូបមួយទៀត<នៅមុនមនុស្សម្នាក់ដែលយើងទើបតែឃើញនៅលើអេក្រង់នេះ។> តើមនុស្សម្នាក់មួយទៀតហ្នឹង តាសាន ដែរទេ?

**ឆ៖** ចាស ខ្ញុំស្គាល់តែរូបហ្នឹង តាសាន ព្រះកេសត្រងិល។ ពីមុនគាត់នៅក្មេង ឥឡូវគាត់ចាស់ហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

ខ្ញុំសូមត្រឡប់មកក្រោយវិញ ខាល់មកក្រោយមកវិញ ព្រោះមុននឹងយើងឃើញរូបមួយផ្សេងទៀត ហើយបន្ទាប់មកយើងស្តុកកន្លែងមុនមនុស្សហ្នឹងដដែល ហើយខ្ញុំនឹងសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីនេះ។

**<កញ្ញា អង់តា ហ្គិសសេ៖>**

លោកចៅក្រម ឡាវ៉ែន៍ មុននឹងចាក់រូបផ្សេងទៀត ដើម្បីជាប្រតិចារឹក សូមលោកចៅក្រមបញ្ជាក់ថាយើងឈប់នៅនាទីណាៗ ហើយនៅនាទីណាដែលដើមបណ្ដឹងរដ្ឋប្បវេណីគាត់ថាគាត់ស្គាល់។ បើមិនអ៊ីចឹងពេលដែលយើងអានប្រតិចារឹក យើងវង្វេងហើយ <គឺបាត់ព័ត៌មានលម្អិត>។

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

បាទអត់អីទេអ៊ីចឹង ខ្ញុំឯកភាព។ ប៉ុន្តែខ្ញុំគិតថាព័ត៌មានហ្នឹងគឺអាចកត់នៅក្នុងប្រតិចារឹកបានហើយ

។ <ខ្ញុំមិនមានព័ត៌មាននៅក្នុងដៃទេ។>

**កញ្ញា អង់តា ហ្គីសសេ៖**

យើងៗអាចឃើញម៉ោង ឃើញនាទីនៅក្នុងអេក្រង់ហើយ <ពេលនេះយើងនឹងបង្ហាញវីដេអូហ្នឹងម្តងទៀត> អ៊ីចឹងយើងអាចដាក់នាទី ដាក់អីទៅបាន យើងដាក់នៅខាង -- យើងឃើញនាទីនៅខាងឆ្វេងអ៊ីចឹងហើយ។ អ៊ីចឹងយើងអាចដាក់បាននៅក្រោមរូបហ្នឹង។

**ប្រធានអង្គជំនុំ៖**

អាយ.ធី ចាក់ផ្សាយម្តងទៀត វីដេអូអម្បាញ់មិញនេះ!

*(ការបង្ហាញឯកសារជាវីដេអូ-រូបភាព)*

[១០:៥៧:២១]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ស្តុបៗ។ ខ្ញុំដូចពិបាកមើល តិចទេនាទី ប្រហែលជា៤៣នាទី ២៧វិនាទី។ លោកស្រីៗស្គាល់មនុស្សហ្នឹងទេ?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស ខ្ញុំស្គាល់។

**ស៖** តើគាត់ហ្នឹងជាអ្នកណា?

**ឆ៖** តាសាន។

**ស៖** អ៊ីចឹងសូមចាក់វីដេអូបន្តទៅទៀត។

*(ការបង្ហាញឯកសារជាវីដេអូ-រូបភាព)*

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ស្តុបៗ ឥឡូវនេះនៅម៉ោង៤៣នាទី ៣៤វិនាទី លោកស្រី តើលោកស្រីស្គាល់មនុស្សម្នាក់ហ្នឹងទេ?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស ខ្ញុំស្គាល់។

**ស៖** តើមនុស្សតែម្នាក់ហ្នឹងទេ តាសាន ហ្នឹងដដែលទេ?

**ឆ៖** ចាស។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** សូមអរគុណលោកស្រី។ សម្រាប់ជាប្រតិចារឹក ខ្ញុំគិតថានាទីនោះគឺ៤៣ ហើយវិនាទីទី៣៥ អម្បាញ់មិញនេះ មិនមែន៣៤ទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី។

ជាដំបូងនេះ មេធាវីការពារក្តីលោក នួន ជា។

[១០:៥៩:២៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួន។ តើនៅពេលដែល <យឿន> និយាយអំពីទស្សនកិច្ចរបស់មេដឹកនាំហ្នឹង តើ <យឿន> ហ្នឹងធ្វើម៉េចបានជា <យឿន> ហ្នឹងគាត់ដឹងថាមេដឹកនាំហ្នឹងគឺជា ខៀវ សំផន, នួន ជា និងប៉ុល ពត?

**លោកស្រី អ៊ុំង សារឿន៖**

**ឆៈ** ចាស គាត់ជាប្រធានកង កង៣។ គាត់អ្នកមូលដ្ឋាន។

**សៈ** ខ្ញុំយល់ហើយ ប៉ុន្តែនៅពេលដែលគាត់និយាយជាមួយលោកស្រី តើគាត់បានប្រាប់លោកស្រីថា គាត់ស្គាល់មេដឹកនាំទាំងអស់ហ្នឹងដោយរបៀបណា ថាមេដឹកនាំ<ដែលលោកស្រីទើបឃើញហ្នឹង គឺប្រាកដ>ជា ប៉ុល ពត, នួន ជា និង ខៀវ សំផន?

**ឆៈ** ចាស ពីឆ្នាំ៧៧ ប៉ុន្តែមិនដឹងថ្ងៃខែ ខ្ញុំអត់ចាំ។

**សៈ** ខ្ញុំសូមសួរជារបៀបផ្សេងទៅវិញ លោកប្រធាន តើ <យឿន>នៅពេលនិយាយជាមួយលោកស្រីអំពីដំណើរទស្សនកិច្ចរបស់មេដឹកនាំ តើ <យឿន> បានប្រាប់លោកស្រី <យឿន> ខ្លួនឯងហ្នឹងស្គាល់មនុស្សទាំងអស់ដែលទៅធ្វើទស្សនកិច្ចហ្នឹង គឺជា ប៉ុល ពត, នួន ជា, ខៀង សំផន ដោយរបៀបណាទេ?

**ឆ៖** គាត់ស្គាល់ខ្លួនឯង។

[១១:០១:៣៧]

**ស៖** តើ <យឿន>មានប្រាប់លោកស្រីថា <>គាត់ស្គាល់មេដឹកនាំទាំងនេះ<ដោយ>ផ្ទាល់<> ឬក៏យ៉ាងណា?

**ឆ៖** គាត់បានថាគាត់ស្គាល់ខ្លួនឯង។ គាត់បាននិយាយតែប៉ុណ្ណឹង។

**ស៖** ដូច្នេះ គាត់មិនបាននិយាយប្រាប់លោកស្រីថាធ្លាប់បានជួបមេដឹកនាំទាំងនេះពីមុន ធ្លាប់បានឃើញនៅក្នុងទស្សនាវដ្ដី ឬក៏ធ្លាប់បានឃើញនៅក្នុងពេលប្រជុំ មានប្រាប់ក្នុងរបៀបណាមួយដែលខ្ញុំបញ្ជាក់នេះទេ?

**ឆ៖** ចាស អត់។ គាត់អត់មានប្រាប់ផង។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីទើបតែឆ្លើយទៅនឹងសំណួររបស់ចៅក្រមដែលថាអង្គការថ្នាក់លើនេះគឺថា ពេលចុះទៅមើលនោះ មានចម្ងាយ៥-៦ម៉ែត្រពីលោកស្រី។ គឺចម្ងាយហ្នឹងចម្ងាយប្រហែលៗជាកន្លែងដែលលោកស្រីកំពុងអង្គុយហ្នឹង ហើយមកខ្ញុំនេះ ខ្ញុំកំពុងតែសួរលោកស្រី ចម្ងាយប្រហែលប៉ុណ្ណឹង ឬក៏អត់ទេ?

**ឆ៖** ចាស។

**ស៖** ហើយនៅពេលលោកស្រីមើលមកខ្ញុំនេះ លោកស្រីមើលឃើញមុខខ្ញុំច្បាស់ទេ?

**ឆ៖** ឃើញច្បាស់។

[១១:០៣:៣២]

**ស៖** តើវាត្រឹមត្រូវដែរឬក៏អត់ទេ នៅពេលដែលលោកស្រីឃើញថ្នាក់ដឹកនាំហ្នឹង អង្គការជាថ្នាក់ដឹកនាំហ្នឹង គឺថាមានតាម៉ុក មួយក្នុងចំណោមហ្នឹង។ តើអ៊ីចឹង ឬក៏អត់ទេ?

**ឆ៖** ចាសៗ។

**ស៖** លោកស្រីក៏បានជម្រាបជូនតុលាការដែលថា លោកស្រីស្គាល់តាម៉ុក ច្បាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតចាក់ -- បាទ ខ្ញុំសូមបង្ហាញអ្វីដែលក្រុមយើងខ្ញុំបានរៀបចំរូបកាលពីម្សិលមិញ គឺមានរូបថតចំនួន១០សន្លឹក។ គោលបំណងនៃការបង្ហាញរូបថតទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺសួរ ចង់សួរគាត់ថាតើគាត់អាចចង្អុលបង្ហាញថា រូបមួយណានៅក្នុងបណ្ដារូបថតទាំង

នេះជារូបតាម៉ុក។ សូមការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទៅយកផ្ទាំងរូបថតដែលរៀបចំឡើងដោយក្រុមមេធាវីការពារក្តី យកទៅដាក់ជូនដើមបណ្តឹងរដ្ឋប្បវេណីពិនិត្យ!

[១១:០៥:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកស្រី-->

**ប្រធានអង្គជំនុំ៖**

ដោយគាត់អត់ចេះអក្សរ លោកមន្ត្រីរដ្ឋបាលតុលាការនៅៗអង្គុយហ្នឹង ចាំសម្របសម្រួលតាមការចង្អុលបង្ហាញរបស់គាត់ នៅពេលដែលភាគីពាក់ព័ន្ធសួរសំណួរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី សូមពិនិត្យមើលទៅ ហើយលោកស្រីអាចចង់ចំណាយពេលប៉ុន្មានក៏បានដែរ ពិនិត្យមើល<ទាំង១០នេះ>ឲ្យបានហ្មត់ចត់ទៅ។ ហើយក្រោយមកសូមប្រាប់ទៅមន្ត្រីតុលាការហ្នឹងដើម្បីឲ្យជម្រាបជូនទៅអង្គជំនុំជម្រះ ថា "នេះ រូបនេះគឺជារូប តាម៉ុក" អ៊ីចឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំឃើញថាមន្ត្រីតុលាការកំពុងតែនិយាយស្អីមួយជាមួយជាដើមបណ្តឹងរដ្ឋប្បវេណី?

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីស្គាល់ តាម៉ុក នៅក្នុងចំណោមរូបថតទាំងនេះទេ?

**លោកស្រី អ៊ុំង សារឿន៖**

**ឆ៖** ចាស គាត់នៅក្មេងពាក់មួកអ៊ីចឹង ខ្ញុំមើលអត់យល់ អត់ស្គាល់។ ធ្លាប់ឃើញគាត់ ដើរអត់សូវឃើញពាក់មួកផង គាត់ជិះឡានមក។ គាត់នៅក្មេងពីមុន អត់ស្គាល់។

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី <>សូមឲ្យលោកស្រីប្រាប់ទៅមន្ត្រីតុលាការដែលកំពុង

អង្គុយក្បែរលោកស្រី ថាប្រសិនណាលោកស្រីអាចស្គាល់រូបណាមួយ ចង្អុលទៅរូបហ្នឹង ហើយដើម្បីឲ្យមន្ត្រីតុលាការជម្រាបជូនទៅតុលាការ។

**ប្រធានអង្គជំនុំ៖**

ស្គាល់ដែរទេ លោកស្រីស្គាល់រូបទាំង១០ហ្នឹង តើស្គាល់បុគ្គលណាមួយដែរឬទេ? បើអត់ស្គាល់ឆ្លើយថាអត់ស្គាល់ទៅចប់ហើយ។

[១១:០៨:០០]

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស អត់ស្គាល់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមសួរសំណួរពីរបីទៀត។ លោកស្រីបាននិយាយថា លោកស្រីនៅក្នុងចម្ងាយមួយជិតនៅពេលដែលឃើញថ្នាក់ដឹកនាំហ្នឹងទៅពិនិត្យកន្លែងធ្វើការ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកមន្ត្រីតុលាការសូមមកកន្លែងដើមវិញមក ខ្ញុំចង់សួរទៅដើមបណ្ដឹងរដ្ឋប្បវេណី។ <លោកស្រីនិយាយថា លោកស្រីស្គាល់ថ្នាក់ដឹកនាំដទៃទៀត។ តើលោកស្រីមានស្គាល់នរណាក្នុងរូបថតហ្នឹងទេ?>

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅ? សាក្សីដូចឆ្លើយច្បាស់លាស់ហើយរូបទាំង១០ហ្នឹងគាត់មិនស្គាល់បុគ្គលណាមួយទេ។ តើមានសំណួរអ្វីពាក់ព័ន្ធនឹងការមិនស្គាល់នេះទៀតដែរឬទេ? ឬក៏លោកមានបំណងសួរដឹកមុខ?

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាមានបញ្ហាបកប្រែលោកប្រធាន។ ខ្ញុំឮថាគាត់មិនស្គាល់តាម៉ុក ទេ។ ខ្ញុំ<មិនដឹងដែរ ឬប្រហែលជាគាត់មិនស្គាល់នរណាទេ ពីព្រោះបើសិន>--

**ប្រធានអង្គជំនុំ៖**

លោកស្រី អ៊ុង សារឿន តើរូបទាំង១០ ដែលដាក់ឲ្យលោកស្រីមើលហ្នឹង លោកស្រីស្គាល់បុគ្គលណាមួយដែរឬទេ?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស អត់។ រូបនៅក្មេង អត់--

**ប្រធានអង្គជំនុំ៖**

រូបទាំង១០ ទាំងអស់ហ្នឹង សួរមួយផ្ទាំងហ្នឹង តើលោកស្រីស្គាល់បុគ្គលណាមួយដែរឬទេ? លោកស្រីស្ដាប់យើងយល់ទេ? ស្ដាប់សំណួរយើងយល់ទេ? រូបទាំង១០នេះ គឺរូបបុគ្គលខុសគ្នា ទាំង១០នាក់នេះ! សំណួរសួរថាតើរូបទាំង១០នេះ លោកស្គាល់បុគ្គលណាមួយដែរឬទេ ក្នុងចំណោមទាំង១០ហ្នឹង មិនសួរតែបុគ្គលណាមួយទេ?

[១១:១០:១៩]

**លោកស្រី អ៊ុំង សារឿន៖**

**ឆ៖** ចាស អត់។ គាត់ពាក់មួកអ៊ីចឹង មើលអត់ស្គាល់។

**លោក វិចទ័រ កូប៉េ៖**

បាទ ខ្ញុំឈប់សួរអំពីប្រធានបទនេះហើយ លោកប្រធាន។ លោកស្រី <ខ្ញុំមានពីរបី>--

**ប្រធានអង្គជំនុំ៖**

ត្រឡប់មកវិញ មកកាន់កន្លែងអង្គុយរបស់លោកវិញ!

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនតូចទេ។ ព្រឹកមិញនេះ លោកស្រីបានឆ្លើយថាកូនលោកស្រីដែលមានអាយុ១ឆ្នាំ គឺថាបានស្លាប់ដោយសារតែជំងឺកញ្ជ្រិល។ លោកស្រីមានចាំទេ តើមានក្មេងៗដទៃទៀតនៅឃុំលាយបូរ <ឬក្នុង>ស្រុកត្រាំកក់ហ្នឹង ស្លាប់នៅអាយុក្មេងៗដោយសារតែជំងឺកញ្ជ្រិលដែរឬទេ?

**លោកស្រី អ៊ុំង សារឿន៖**

**ឆ៖** ចាស មាន អាយុ២ឆ្នាំ ៣ឆ្នាំ ស្លាប់ច្រើន ឲ្យយាយៗមើល។

**ស៖** លោកស្រីចាំទេ មានក្មេងតូចៗហ្នឹងប្រហែលជាប៉ុន្មាននាក់ស្លាប់ដោយសារជំងឺកញ្ជ្រិល? ពីរបី ឬក៏ច្រើន លោកស្រីអាចចាំចំនួនប្រហាក់ប្រហែលបានទេ?

**ឆ៖** ចាស នៅជិតផ្ទះខ្ញុំហ្នឹង កុមារៗតូចៗហ្នឹង នៅកន្លែងកងពាហ្នឹង ស្លាប់ ខ្ញុំដឹង ចំនួនជាប្រាំពីរ ប្រាំបីនាក់។

[១១:១២:៣០]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំមានសំណួរមួយ គឺពាក់ព័ន្ធទៅនឹងអ្វីលោកស្រីបានឆ្លើយកាលពីព្រឹកមិញថា ប្រជាជនមូលដ្ឋានមានម្ហូបអាហារគ្រប់គ្រាន់ ក៏ប៉ុន្តែប្រជាជន១៧មេសា មិនមានអាហារហូបគ្រប់គ្រាន់ទេ។ តើលោកស្រីអាចជម្រាបជូនតុលាការថា លោកស្រីដឹងបញ្ហានេះ ដឹងបញ្ហាថាអ្នកមូលដ្ឋានមានម្ហូបអាហារគ្រប់គ្រាន់ អ្នក១៧មេសាមិនមានម្ហូបអាហារគ្រប់គ្រាន់។ លោកស្រីដឹងដោយរបៀបណា? <តើលោកស្រីសង្កេតឃើញអ្វីខ្លះពាក់ព័ន្ធនឹងបញ្ហាហ្នឹង?>

**ឆ៖** ចាស គាត់ហូបគ្រប់គ្រាន់ហ្នឹង គាត់មកប្រាប់ គាត់និយាយ មកសួរ។ អ្នកស្គាល់ ស្រុកភូមិជាមួយខ្ញុំហ្នឹង។

**ស៖** អ៊ីចឹង តើៗធ្វើម៉េចបានជាលោកស្រីដឹងថាប្រជាជន១៧មេសា មិនមានម្ហូបអាហារគ្រប់គ្រាន់?

**ឆ៖** ចាស នាងខ្ញុំដឹង ឪពុកម្ដាយខ្ញុំ ខ្ញុំ ដួសបបរចែកក្នុងឆ្នាំងមួយអ៊ីចឹង បួននាក់។ ជួនណាដួសដាក់ចាន មួយវែកៗអ៊ីចឹង ដាក់ឲ្យ បួននាក់ហូបទៅ។

**ស៖** ប៉ុន្តែនៅ<ពេលចាប់ផ្តើម> គឺក្នុងឆ្នាំ៧៥, ៧៦ តើលោកស្រីហូបរួមនៅក្នុងសហករណ៍រួមជាមួយនឹងប្រជាជនមូលដ្ឋានដែរឬទេ? គឺចង់សួរថាតើប្រជាជន១៧មេសា ហើយនិងប្រជាជនមូលដ្ឋានហូបជាមួយគ្នាឬអត់ទេ?

**ឆ៖** ចាស ពីមុនអ្នកប្រជាជន១៧ ហើយប្រជាជនភេទទី២ ហូបរួមគ្នា។ ដល់តែពេលក្រោយស្រង់ឈ្មោះប្រជាជន១៧ ដាក់ផ្សេង ប្រជាជនទី២ ពាក់ព័ន្ធហ្នឹងផ្សេង ទី១ផ្សេង។

[១១:១៥:00]

**ស៖** បើខ្ញុំយល់មិនច្រឡំទេ នៅពេលដែលប្រជាជនមូលដ្ឋាន និងប្រជាជន១៧មេសា ហូបបាយរួមគ្នា ប្រជាជនទាំងពីរប្រភេទនេះគឺថាទទួលបានចំណីអាហារហ្នឹងគឺថាដូចៗគ្នាទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស អត់ទេ អត់ដូចទេ។

**ស៖** លោកស្រី គឺក៏ហូបរួមជាមួយអ្នកមូលដ្ឋាន ប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋានគេហូបរួមគ្នា ចម្រុះគ្នា។ អ៊ីចឹងធ្វើម៉េចបានប្រជាជនមូលដ្ឋានមានម្ហូបចំណីអាហារច្រើនជាង ប្រជាជន១៧មេសា បើហូបរួមនៅសហករណ៍តែមួយអ៊ីចឹង?

**ឆ៖** កាលហ្នឹង ចេញដំបូង ឲ្យមានគាត់មានផ្ទះ មានទីលំនៅ នៅស្រួលក៏ឲ្យចតនៅក្បែរៗហ្នឹងអ៊ីចឹងទៅ ហើយដល់ពេលៗបំបែក ហូបផ្សេង។

**ស៖** បាទ ខ្ញុំយល់ ក៏ប៉ុន្តែខ្ញុំសួរថានៅពេលដែលប្រជាជនទាំងអស់ហូបចុករួមគ្នា ប្រជាជនមានរបបអាហារដូចៗគ្នាទេ តើអ៊ីចឹងឬក៏អត់ទេ?

**ឆ៖** ចាស អត់ទេ។ ១៧ ចែកដាច់ហ្នឹង ក្រោយហ្នឹងចែកដាច់។ អត់ឲ្យច្រឡូកច្រឡំជាមួយមូលដ្ឋាន។

**ស៖** តែសំណួររបស់ខ្ញុំអ៊ីចេះលោកស្រី នៅពេលដែលប្រជាជនទាំងអស់ហូបរួមគ្នា ចម្រុះគ្នា គឺថាតើពេលនុំងពេលដែលហូបរួមគ្នាហ្នឹង តើប្រជាជនទាំងអស់ហ្នឹងគឺមានរបបអាហារដូចៗគ្នា ឬក៏អត់ទេ?

**ឆ៖** ចាស អត់។

**ស៖** សូមលោកស្រីជម្រាបជូនតុលាការបន្តិចមក នៅពេលដែលលោកស្រីហូបរួមគ្នា ហេតុអ្វីបានជាអ្នកមូលដ្ឋានទទួលបានបបរ ទទួលបានសម្ល ទទួលបានបាយទឹកច្រើនជាង?

**ឆ៖** ចាស គាត់អ្នកមូលដ្ឋាន គាត់មានសិទ្ធិសុំគ្នាគាត់បាន។ បើនាងខ្ញុំ១៧ អត់ហ៊ានចូលទៅចង្ក្រានបាយទេ គេអាចខ្លាចដាក់ថ្នាំបំពុល អត់ឲ្យចូលជិតទេ។ ដល់ពេល បានឲ្យមកហូប។ ចាស់ដើរមិនរួចឲ្យបបរមកផ្ទះ អ្នកឈឺដកបបឲ្យមកផ្ទះ។

**ស៖** តែនៅលើគុ នៅពេលដែលមនុស្សហូបរួមគ្នា គេៗឲ្យចំណីអាហារហ្នឹងដូចៗតែគ្នាទេ។ តើអ៊ីចឹងឬក៏អត់ទេ?

**ឆ៖** ចាស អត់ទេ។ ដូចគ្នាតែអ្នក១៧ ឲ្យហូបមុន។ អ្នកមូលដ្ឋានគាត់ហូបពេលក្រោយគ្នាគាត់អ្នកចុងភៅបានម្ហូបត្រីធំៗគាត់ គ្នាគាត់ស៊ី អត់ឲ្យខ្ញុំដឹងផង។ ១៧ គាត់ចែកបាយម្ហូបហ្នឹងឲ្យមុន។

**ស៖** ចុះអ្នកដែលទទួលខុសត្រូវនៅរោងបាយ<រួម>ហ្នឹង ដឹងថាអ្នកណាជាប្រជាជន១៧មេសា អ្នកណាជាប្រជាជនមូលដ្ឋាន? តើៗអ្នកគ្រប់គ្រងនៅកាស៊ីនបាយហ្នឹង សហករណ៍ហ្នឹង ដឹងដោយរបៀបណា?

[១១:១៩:៤៨]

**ឆ៖** ដើរកត់ឈ្មោះ។ មេភូមិ មេក្រុមៗកត់ឈ្មោះឲ្យមេភូមិ។ មេភូមិដឹងបែងចែក។

**ស៖** ពេលនោះហូបបីពេលក្នុងមួយថ្ងៃ មានអាហារពេលព្រឹក ថ្ងៃត្រង់ ល្ងាច អ៊ីចឹងឬក៏អត់ទេ?

**ឆ៖** ចាស អត់ទេ មានតែពីរ ថ្ងៃត្រង់ ល្ងាច។ ព្រឹកអត់មានទេ។

**ស៖** អាហារ គឺ<ផ្តល់ឲ្យ>តែពីរដងទេ ក្នុងមួយថ្ងៃ <គឺពេលព្រឹក និងពេលល្ងាច>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចាស ក្នុងមួយថ្ងៃហូបតែពីរដង ព្រឹក ហើយល្ងាច។

**ស៖** សំណួររបស់ខ្ញុំនោះគឺ ប្រសិនបើអ្នកណាម្នាក់មានចំណីអាហារហូបច្រើនជាងនោះ ខ្ញុំចង់យល់ថា តើគេបានច្រើនដោយរបៀបណា?

**ឆ៖** គាត់ធ្វើចុងភៅខ្លួនឯង ហើយគាត់គ្នាគាត់ចាស់ៗ គាត់ស្គាល់គ្នាគាត់ គាត់ធ្លាប់រស់នៅពីមុនៗ ពីឆ្នាំ៧០, ៧១, ៧២, ៧៣ អីចឹងទៅ គាត់ស្គាល់គ្នាគាត់។ ហើយបើអ្នក១៧មេសា ចេញមកពីឆ្នាំ៧៥ គេស្គាល់។ ស្រង់ឈ្មោះឲ្យគេដឹងអស់ហើយ។

**ស៖** ពីមុន ពីព្រឹកមិញ លោកស្រីនិយាយអំពីការសម្លាប់កុមារម្នាក់អាយុ១៥ឆ្នាំ ដោយសារតែលួចចំណីអាហារ។ ប៉ុន្តែនៅពេលដែលលោករំឭករឿងនេះឡើង លោកស្រីថា លោកស្រីខ្លួនឯងក៏ធ្លាប់បានលួចចំណីអាហារ និងម្ហូបអាហារម្តងដែរ។ ប៉ុន្តែគេគ្រាន់តែកសាង អប់រំកសាងលោកស្រី ហើយក៏ឲ្យមកវិញ។ ចុះម៉េចបានជាក្មេងអាយុ១៥ឆ្នាំលួចចំណី គេសម្លាប់ ហើយលោកស្រីអត់អី?

**ឆ៖** ចាស កុមារលួចបាយទៅ ហើយយកទៅសម្លាប់។ ដូចខ្ញុំ ដាក់វិន័យឲ្យខ្ញុំ ខ្ញុំក៏កសាងខ្លួនថ្ងៃមុខ ថ្ងៃក្រោយខ្ញុំថា អត់ហ៊ានលួចទៀតទេ។ ហើយក៏យកខ្ញុំទៅទារុណកម្មទៅចម្ការសៀងទៅ។

[១១:២៣:០៨]

**ស៖** លោកស្រីពន្យល់ផងថាហេតុអ្វី គេគ្រាន់តែព្រមានលោកស្រី? ឯកុមារហ្នឹងមិនទទួលបាន- -មិនគ្រាន់តែទទួលបានការព្រមាន តែបែរទៅជាសម្លាប់។ លោកស្រីអាចបញ្ជាក់ចំណុចខុសគ្នានេះ បានទេ?

**ឆ៖** សេដ្ឋកិច្ចហ្នឹងរាយការណ៍ទៅគ្រូសិក្សា។ គ្រូសិក្សាហ្នឹង គេឲ្យនីរសារមកយកកុមារទៅបាត់ទៅ។

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះឯកសារ D22/2500 ERN ជាភាសាអង់គ្លេស 01069306, ខ្មែរ -- ខ្ញុំអត់មានERN ជាភាសាខ្មែរទេ។ ខ្ញុំនឹងរក ERN ជាភាសាខ្មែរទៅឲ្យនៅពេលក្រោយលោកប្រធាន។ លោកស្រីៗបាននិយាយថា លោកស្រីមិនមែន<>ចេះតែភ្លេចភ្លាំងទេ គឺថាលោកស្រីមានជំងឺសរសៃប្រសាទទៀតផង។ លោកស្រីតើធ្វើម៉េចបានដឹងថា លោកស្រីមានបញ្ហាសរសៃប្រសាទ?

**ឆ៖** កាលហ្នឹងនាងខ្ញុំសម្រាន្តអត់លក់ ហើយរសេះរសោះ ហើយដល់ពេលខ្ញុំនឹកឃើញរឿងដើមអីចឹង រសេះរសោះអីចឹង សម្រាន្តអត់លក់ ខ្ញុំរសាប់រសល់ ប៉ុន្តែនាងខ្ញុំចងចាំទាំងអស់។ ខ្ញុំដាក់ទៅ ខ្ញុំចង

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01468787


ចាំ។

[១១:២៥:០០]

**ស៖** ខ្ញុំយល់ហើយលោកស្រី។ ការដែលសម្រាន្តមិនលក់វាជាបញ្ហាមួយ ក៏ប៉ុន្តែបញ្ហាសរសៃប្រសាទនេះជាបញ្ហាផ្សេង។ តើលោកស្រីអាចជម្រាបជូនតុលាការបានទេ <តើលោកស្រីចង់បានន័យថាម៉េចនៅពេល>លោកស្រីប្រើពាក្យថាបញ្ហាសរសៃប្រសាទ ដើម្បីរៀបរាប់អំពីស្ថានភាពសុខភាពរបស់លោកស្រីនេះ លោកស្រីរៀបរាប់បន្តិចបានទេ?

**ផ៖** ចាស នាងខ្ញុំបើកថ្នាំនៅខាង ភី.ធី.អូ ខ្ញុំអត់ស្គាល់ថ្នាំ បើកថ្នាំ ភី.ធី.អូ អ៊ីចឹងហើយ។

**ស៖** តើអង្គការ ធី.ភី.អូ នេះមានប្រាប់លោកស្រីថា លោកស្រីមានជំងឺអ្វីមួយ គឺជំងឺដូចគេប្រាប់ថាជំងឺបញ្ហាភ្លេចភ្លាំង បញ្ហាសរសៃប្រសាទនេះទេ?

**ផ៖** ចាស ពេលក្រោយ គាត់ថាអត់មានទេ អត់មានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិ ការពារក្តីលោក ខៀវ សំផន ខ្ញុំសួរលោកក្នុងឋានៈជាមេធាវី។ ខ្ញុំនឹងសួរសំណួរច្បាស់ៗខ្លីៗ<មួយចំនួនទៅលោកស្រី។> ដូច្នេះ សូមឲ្យលោកស្រីឆ្លើយឲ្យបានជាក់លាក់ ច្បាស់ ហើយខ្លីទៅនឹងសំណួររបស់ខ្ញុំ។

**ស៖** លោកស្រីបានឆ្លើយអម្បាញ់មិញនេះថា លោកស្រីមកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មកតែម្នាក់ឯងទេ ហើយមកចូលក្នុងបរិវេណតុលាការហ្នឹង ក៏មកតែម្នាក់ឯងដែរមកបំពេញបែបបទរបស់លោកស្រីនោះ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ផ៖** ចាស ត្រឹមត្រូវ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** ខ្ញុំដឹងថាលោកស្រីមិនចេះអាន ចេះសរសេរអីទេ អ៊ីចឹងតើមានអ្នកណាម្នាក់នៅតុលាការហ្នឹងមានជួយលោកស្រីក្នុងការបំពេញបែបបទហ្នឹងទេ?

**ផៈ** ចាស អត់មានទេ ខ្ញុំចងចាំខ្លួនខ្ញុំផ្ទាល់។

[១១:២៨:០០]

**សៈ** ប្រហែលជាយើងយល់គ្នាមិនច្បាស់។ ខ្ញុំសួរលោកស្រីថានៅពេលដែលបំពេញនេះ សរសេរអក្សរនៅលើបែបបទហ្នឹង មានមនុស្សម្នាក់ជួយលោកស្រីកត់ ដូចថាសរសេរតាមលោកស្រី<ប្រាប់>អ៊ីចឹងមែនទេ? លោកស្រីនឹកឃើញរឿងអី លោកស្រីប្រាប់គេ ហើយគេកត់ចូលអ៊ីចឹងទេ?

**ផៈ** ចាស នាងខ្ញុំប្រាប់ រឿងរបស់ខ្ញុំៗប្រាប់ឲ្យគាត់ជួយសរសេរឲ្យ ព្រោះខ្ញុំអត់ចេះអាន។ ខ្ញុំឆ្លើយអ៊ីចឹងមែន។

**សៈ** ហើយបន្ទាប់មកទៀត គេមានអានអ្វីដែលសរសេរនៅក្នុងទម្រង់បែបបទហ្នឹងទេ មុននឹងឲ្យលោកស្រីផ្តិតមេដៃហ្នឹង គេមានអានឡើងវិញឲ្យលោកស្រីស្តាប់ទេ?

**ផៈ** ចាស អានឲ្យស្តាប់។

**សៈ** ក្នុងចំណោមសំណួរដែលនៅក្នុងទម្រង់បែបបទហ្នឹង តើលោកស្រីចាំទេថា មានកូឡោនមួយសម្រាប់និយាយអំពីអ្នកទទួលខុសត្រូវឧក្រិដ្ឋកម្មនៅពេលនោះៗ។ លោកស្រីមានចាំទេ?

**ផៈ** ខ្ញុំអត់ចាំ។

**សៈ** អម្បាញ់នេះ លោកស្រីឆ្លើយថាលោកស្រីស្គាល់ តាម៉ុក ដោយសារតែលោកស្រីបានឃើញគាត់នៅក្នុងស្រុករបស់លោកស្រីនៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩។ អ៊ីចឹងលោកស្រីនៅរក្សាចម្លើយហ្នឹងទេ?

**ផៈ** ចាស ខ្ញុំទទួល ខ្ញុំស្គាល់ ប៉ុន្តែរូបថតគាត់មក ស-ខ្មៅ ក្មេង ខ្ញុំអត់សូវចងចាំ។

[១១:៣០:១៣]

**សៈ** លោកស្រីក៏បានឆ្លើយផងដែរថា លោកស្រីមិនស្គាល់លោក ខៀវ សំផន ទេ ក៏ប៉ុន្តែលោកស្រីធ្លាប់ឮឈ្មោះគាត់តាមរយៈឰរបស់លោកស្រី។ ហើយលោកស្រីបានឃើញគាត់ម្តងនៅពេលដែលគាត់ចុះមកមើលការដ្ឋានដែលលោកស្រីធ្វើការ។ តើអ៊ីចឹងមែនទេ គឺលោកស្រីបានឃើញតែម្តងគត់ឃើញលោក ខៀវ សំផន នៅការដ្ឋានដែលលោកស្រីធ្វើការ?

**ផៈ** ចាស នាងខ្ញុំឃើញតែម្តងគត់ អត់ដែលឃើញ -- ឪពុកមាគាត់អានកាសែតគាត់ប្រាប់។

គ្រាន់តែឃើញខ្លួនផ្ទាល់ ឃើញតែមួយសា។ ខ្ញុំអត់ចងចាំទេ ខ្ញុំអត់សូវបានមើលផង ខ្ញុំកំពុងធ្វើការងារ។

**ស៖** អ៊ីចឹងយើងឯកភាពគ្នាទេថា ក្រោយពីមេដឹកនាំ និងលោក ខៀវ សំផន ចាកចេញទៅមេកងរបស់លោកស្រីហ្នឹង គាត់ប្រាប់ឈ្មោះៗ ថាមេដឹកនាំនេះឈ្មោះអីៗខ្លះដែលមកហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ដែលគាត់ត្រឡប់ទៅវិញ គាត់ខ្សឹបប្រាប់នាងខ្ញុំ។

**ស៖** តើលោកស្រីធ្លាប់<ឮ>គេនិយាយពីឈ្មោះ អៀង សារី ទេនៅសម័យនោះ?

**ឆ៖** ចាស ដែលឮ អៀង សារី។ ធ្លាប់ឮ តែខ្ញុំអត់ស្គាល់គាត់ទេ គ្រាន់ឮឈ្មោះ។

**ស៖** ចុះ កាំង ហ្កេកអ៊ាវ ហៅ ឌុច លោកស្រីធ្លាប់ឮឈ្មោះគាត់ទេ នៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩?

**ឆ៖** ចាស ឌុច ខ្ញុំធ្លាប់ឮ ប៉ុន្តែខ្ញុំអត់ស្គាល់រូបគាត់ទេ ឮ។

**ស៖** ខ្ញុំសួរលោកស្រីច្បាស់ណាស់ថា នៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ គឺពី១៧មេសា ៧៥ ទៅដល់ខែមករា ៧៩ គឺសម័យខ្មែរក្រហមហ្នឹង លោកស្រីធ្លាប់ឮឈ្មោះ ឌុច ហ្នឹងទេ? កាំង ហ្កេកអ៊ាវ ហៅ ឌុច?

**ឆ៖** ខ្ញុំធ្លាប់ឮ តែ៧៩ទេដែលឮ តាឌុច ទួលស្លែង ប៉ុន្តែខ្ញុំអត់ដែរស្គាល់ទេណា។ ខ្ញុំក៏អត់ស្គាល់ទួលស្លែងដែរ។ នាងខ្ញុំទើបនឹងស្គាល់ មានសាច់ញាតិស្លាប់នៅហ្នឹង។

[១១:៣៣:២២]

**ស៖** ខ្ញុំសួរលោកស្រីអំពីបុគ្គលរូបនេះ ពីព្រោះថានៅក្នុងឯកសាររបស់លោកស្រី ដែលនិយាយអំពីទម្រង់បែបបទព័ត៌មានជនរងគ្រោះហ្នឹង គឺឯកសារ<ជាភាសាអង់គ្លេស> D22/2500/1នៅកន្លែងមួយដែលគេនិយាយថា “អ្នកទទួលខុសត្រូវ<ឧក្រិដ្ឋកម្ម>” លោកស្រីបានដាក់ឈ្មោះ តាម៉ុក, ខៀវ សំផន, អៀង សារី, នួន ជា និង កាំង ហ្កេកអ៊ាវ ហៅ ឌុច។ អ៊ីចឹង តើលោកស្រីជាអ្នកបញ្ជាក់ឈ្មោះហ្នឹងមែនទេ នៅថ្ងៃដែលគេសម្ភាសលោកស្រី ដើម្បីបំពេញទម្រង់បែបបទហ្នឹង? ខ្ញុំសូមផ្តល់លេខ ERN គឺ 00550904។ ដូច្នេះ ខ្ញុំចង់សួរលោកស្រីថា ជាលោកស្រីមែនទេ ជាអ្នកផ្តល់ឈ្មោះហ្នឹងនៅពេលដែលគេបំពេញទម្រង់បែបបទឲ្យលោកស្រីហ្នឹង?

**ឆ៖** ចាស នាងខ្ញុំ--

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01468790



កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់បន្តិចពាក់ព័ន្ធទៅនឹងឯកសារនេះ។ មានសំណើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលយើងហៅថាទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ។ ឯកសារនេះជាឯកសារដែលដើមបណ្ដឹង<រដ្ឋប្បវេណី>ចុះហត្ថលេខា បន្ទាប់មកទៀតមានឯកសារមួយទៀត ដែលឯកសារហ្នឹងសរសេរ<ព្រាង>ដោយអង្គភាពជនរងគ្រោះ ក្រោយពេលដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង។ វាគ្រាន់តែ>ជាការសង្ខេបរបស់អង្គភាពជនរងគ្រោះ គឺ<ធ្វើសម្រាប់ពាក្យសុំតាំងខ្លួនជា>ដើមបណ្ដឹងរដ្ឋប្បវេណី<ទាំងអស់។ ហើយឯកសារទាំងអស់ហ្នឹង គឺមិន>បានចុះហត្ថលេខា<ផ្ទាល់ ដោយជនរងគ្រោះនោះទេ>។ ខ្ញុំនិយាយនេះជាលក្ខណៈទូទៅដើម្បីឲ្យដឹងថាតើឯកសារហ្នឹងជាឯកសារអ្វី? គឺមានឯកសារមួយដែលចុះហត្ថលេខាផ្ទាល់ដោយ<ជនរងគ្រោះ> ហើយនិងមានរបាយការណ៍មួយទៀត <ដែលត្រូវបានរៀបចំដោយ>អង្គភាព<គាំពារ>ជនរងគ្រោះដែលគាត់មិនបានចុះហត្ថលេខាទេ។ អ៊ីចឹង ខ្ញុំធ្វើអ៊ីចឹងពន្យល់បែបនេះ ដើម្បីឲ្យបែងចែកឲ្យដាច់ពីឯកសារទាំងពីរហ្នឹង។

[១១:៣៥:៥៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណចំពោះការបញ្ជាក់នេះ ក៏ប៉ុន្តែខ្ញុំសួរសំណួរទៅគាត់ហ្នឹង គឺដើម្បីឲ្យគាត់ឆ្លើយខ្លួនឯងផ្ទាល់ ដើម្បីឲ្យដឹង ពីព្រោះថាឯកសារគឺថាគាត់ៗជាអ្នកផ្ដិតមេដៃចុះហត្ថលេខាផ្ទាល់<នៅថ្ងៃតែមួយហើយមិនមែនជាការសង្ខេបទេ> យើងឃើញឈ្មោះគាត់ផ្ទាល់ ហើយខ្ញុំមានឯកសារជាភាសាខ្មែរ គឺ D22/2500 ដោយសារតែយើងមិនមានការបកប្រែជាភាសាបារាំង ឬអង់គ្លេស គឺខ្ញុំផ្ដល់តែលេខា ERN ជាភាសាខ្មែរគឺ 00550909 គឺមានបញ្ជាក់ឈ្មោះ ហើយឈ្មោះហ្នឹងគឺមាននៅក្នុងទម្រង់បែបបទហ្នឹងហើយ។

**ស៖** អ៊ីចឹងហើយបានជាខ្ញុំសួរគាត់នោះ ដែលថាគាត់ខ្លួនឯងផ្ទាល់មែនទេ ជាអ្នកប្រាប់ឈ្មោះហ្នឹង?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស ខ្លួនខ្ញុំផ្ទាល់ ខ្ញុំប្រាប់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ដូច្នេះខ្ញុំចង់ដឹងថាហេតុអ្វីបានជាលោកស្រីមិនស្គាល់ពួកគាត់ផង លោកស្រីរៀបរាប់ឈ្មោះពួកគាត់នោះ ហើយនៅចន្លោះឆ្នាំ៧៥ ដល់៧៩ លោកស្រីមិនបាន<ឃើញពួកគាត់>ទេ ដូចជា ឌុច ហើយនិង អៀង សារី នោះ។ លោកស្រីបានឆ្លើយហើយថា លោកស្រីមិនដែលបានឃើញ អៀង សារី និង ឌុច ទេ។ អ៊ីចឹងហេតុអីបានជានៅផ្នែកដែលថា អ្នកណាដែលជឿជាក់ថាជាអ្នកទទួលខុសត្រូវហ្នឹង លោកស្រីដាក់ឈ្មោះពួកគាត់ទាំងអស់ហ្នឹង។

**ឆ៖** ចាស ឪពុកមាហ្នឹងអានកាសែតឲ្យស្ដាប់។

[១១:៣៧:៤៣]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី តើត្រូវចំណាយពេលវេលាប្រហែលប៉ុន្មានទៀតទៅ ក្នុងការសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ?

**កញ្ញា អង់តា ហ៊្គីសសេ៖**

មេធាវី កូប៉េ បានចាប់ផ្ដើមនៅម៉ោងដប់មួយ អ៊ីចឹងខ្ញុំគិតថាខ្ញុំត្រូវការពេលដល់ម៉ោងដប់ពីរថ្ងៃត្រង់ ព្រោះថាយើងបែងចែកពេលទៅ ម្នាក់កន្លះម៉ោង។ អ៊ីចឹងរហូតទៅដល់ថ្ងៃត្រង់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកស្រីចង់បន្តសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះតទៀត ឬក៏សម្រាក? ព្រោះពាក់ព័ន្ធជាមួយនឹងការសម្រេចរបស់អង្គជំនុំជម្រះ ដែលគិតគូដល់សុខភាពរបស់កូនក្ដីរបស់លោកស្រី លោក ខៀវ សំផន ដែលស្នើសុំឲ្យអង្គជំនុំជម្រះធ្វើសវនាការយ៉ាងយូរត្រឹមម៉ោងដប់មួយ សាមសិបនាទី។

**កញ្ញា អង់តា ហ៊្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏គិតដល់ចំណុចហ្នឹងដែរ អ៊ីចឹងខ្ញុំគិតថាបើយើងបញ្ចប់ដល់ម៉ោងដប់ពីរ ហើយនៅរសៀលហ្នឹង អត់មានសវនាការ អ៊ីចឹងអត់អីទេ កូនក្ដីខ្ញុំអាចសម្រាកបាននៅពេលរសៀល។ អ៊ីចឹងអ្វីៗសម្រេចទៅលើអង្គជំនុំជម្រះ លោកប្រធាន។ <ដូច្នេះ ខ្ញុំនឹងប្រាប់ទៅកូនក្ដីរបស់ខ្ញុំ ហើយនិងសួរបញ្ជាក់គាត់។>

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបន្ត។

[១១:៣៩:១៧]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01468792



**កញ្ញា អង់តា ហ្គីសសេ៖**

ដោយសារតែរសៀលនេះមិនមានសវនាការទេ<ហើយកូនក្ដីរបស់ខ្ញុំមិនមានបញ្ហានោះទេ> អ៊ីចឹងអាចបន្តទៀតបានលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បន្តទៀតចុះ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងខ្ញុំសួរ ខ្ញុំដូចជា ខ្ញុំបានសួរអម្បាញ់មិញហើយថា ហេតុអ្វីបានជាលោកស្រីដាក់ឈ្មោះបុគ្គលទាំងអស់ហ្នឹង ដូចជាឧទាហរណ៍ អៀង សារី, កាំង ហ្កេកអ៊ាវ ហៅ ឌុច។ <បើសិន>លោក<ស្រីមិន>បានឃើញពួកគាត់ទេនៅសម័យនោះៗ ហើយក៏មិនដែលជួបពួកគាត់ដែរនៅត្រាំងកក់នោះ។ ហេតុអីបាននៅជានៅក្នុងហ្នឹង លោកស្រីដាក់ឈ្មោះ អៀង សារី និង ឌុច នោះ?

[១១:៤០:០៧]

**លោកស្រី អ៊ុំ សារឿន៖**

**ឆ៖** ចាស ឪពុកមាខ្ញុំប្រាប់ ឪពុកខ្ញុំប្រាប់ ចាស់ៗគាត់ស្គាល់ ហើយខ្ញុំចាំ ព្រះជន្មគាត់សព្វថ្ងៃគាត់នៅ ៨៨-៩០ ជាង។

**ស៖** នៅពេលដែលលោកស្រីនិយាយថា ឪពុកមាប្រាប់នោះ គឺថាគាត់ឃើញឈ្មោះអ្នកណានៅក្នុងកាសែតហ្នឹង?

**ឆ៖** ឃើញតា ខៀវ សំផន ហើយនិងអៀង សារី។

**ស៖** អ៊ីចឹង ឪពុកមារបស់លោកស្រីឃើញឈ្មោះ ពួកគាត់ហ្នឹងនៅក្នុងកាសែតហ្នឹងនៅពេលណា? មុនឆ្នាំ៧៥? ក្រោយឆ្នាំ១៩៧៥ ក្រោយ១៩៧៩? អ៊ីចឹងពេលណា ឲ្យច្បាស់ថាឪពុកមារបស់លោកស្រីឃើញឈ្មោះពួកគាត់នៅក្នុងកាសែតហ្នឹង?

**ឆ៖** ចាស គាត់អានហ្នឹងឃើញពីឆ្នាំ ៧៤, ៧៣ គាត់គ្រូបង្រៀននៅខេត្តតាកែវ។

**ស៖** ចុះឈ្មោះ ឌុច? ពូរបស់លោកស្រីហ្នឹង ឃើញឈ្មោះហ្នឹងមុនឆ្នាំ១៩៧៥ ដែរឬទេ?

**ឆ៖** ចាស អត់ទេ ទើបតែឮ៧៩។

**ស៖** អ៊ីចឹងឮក្រោយឆ្នាំ៧៩ហ្នឹង គឺថាមិនមែនពូរបស់លោកស្រីទេ ជាអ្នកប្រាប់លោកស្រីនោះមែនទេ?

**ឆ៖** មា។គាត់នៅធ្វើការនៅភ្នំពេញ នៅក្នុងវាំងពីដើម ឥឡូវគាត់ស្លាប់ហើយ ឈ្មោះ អ៊ំម៉ប អ៊ំយិន។ កូនគាត់នៅក្នុងហ្នឹងទាំងអស់ ស្លាប់ទាំងអស់មួយគ្រួសារ យកសម្លាប់នៅ ជាប់ឃុំឃាំងហើយយកសម្លាប់នៅជើងឯក។ គ្រួសារគាត់អត់មាននៅម្នាក់ទេស្លាប់ទាំងអស់ -- នៅចៅមួយ។

**ស៖** លោកស្រី អ៊ុំង សារឿន ខ្ញុំមានពេលខ្លីណាស់ អ៊ីចឹងសូមឲ្យលោកស្រីឆ្លើយឲ្យបានច្បាស់លាស់ទៅនឹងសំណួររបស់ខ្ញុំ។ ខ្ញុំសួរចង់ដឹងថាតើឈ្មោះ ឌុចនេះ ក៏ត្រូវបានឪពុកមារបស់លោកហ្នឹងអានឲ្យលោកស្រីស្ដាប់ ក្នុងកាសែតដែរមែនទេ?

**ឆ៖** ចាស។

**ស៖** អ៊ីចឹងខ្ញុំចង់ដឹងថា តើនៅពេលណាដែលគាត់អានឈ្មោះរបស់ឌុច ហ្នឹងនៅក្នុងកាសែតហ្នឹងលោកស្រីចាំទេ ឆ្នាំណាដែរ?

**ឆ៖** ចាសខ្ញុំអត់ចាំទេ ឆ្នាំ។

[១១:៤៣:៣៦]

**ស៖** តើក្រោយពេលវៀតណាមចូល ឬក៏មុនពេលវៀតណាមចូល?

**ឆ៖** ខ្ញុំអត់ចាំ។

**ស៖** នៅក្នុងឯកសាររបស់លោក គឺឯកសារ D22/2500 លោកស្រីបានសរសេរឈ្មោះ ខៀវ សំផន, នួន ជា ថាជាអ្នកដែលលោកស្រីជឿជាក់ថាទទួលខុសត្រូវ<ឧក្រិដ្ឋកម្ម>។ ក៏ប៉ុន្តែលោកស្រីមិនបាននិយាយអំពីទស្សនកិច្ចរបស់ពួកគាត់នៅត្រាំកក់ ដែលពេលហ្នឹងលោកស្រីបានឃើញពួកគេទេ។ អ៊ីចឹងខ្ញុំចង់ដឹងថា ហេតុអ្វីបានជានៅក្នុងឯកសារហ្នឹង លោកស្រីមិនបាននិយាយអំពីទស្សនកិច្ចរបស់ពួកគាត់?

**ឆ៖** ខ្ញុំឃើញគាត់ពីឆ្នាំ៧៧ តែម្ដងហ្នឹង។

**ស៖** ខ្ញុំយល់ហើយថាលោកស្រីបានឃើញគាត់ម្ដង ក៏ប៉ុន្តែខ្ញុំសួរលោកស្រីថាហេតុដូចម្ដេចបានជាលោកស្រីមិនដាក់អំពីទស្សនកិច្ចរបស់គាត់នៅក្នុងទម្រង់បែបបទហ្នឹង លោកស្រីដាក់ឈ្មោះ<ពួកគាត់<>។ តើហេតុអ្វីបានជាលោកស្រី<មិនលើកឡើងអំពី>ទស្សនកិច្ច<របស់ពួកគាត់>នៅកន្លែងការដ្ឋានលោកស្រីនោះ?

**ឆ៖** ចាស គឺខ្ញុំអត់សូវដឹង ព្រោះខ្ញុំអត់ចេះអក្សរ។

**ស៖** ខ្ញុំយល់លោកស្រី អ៊ុំង សារឿន។ ក៏ប៉ុន្តែបែបបទហ្នឹងគឺថាបានបំពេញដោយមានអ្នកជួយ

លោកស្រីបំពេញ។ លោកស្រីប្រាប់គាត់ គាត់អ្នកបំពេញ គាត់កត់ត្រានូវព័ត៌មានដែលលោកស្រីបានប្រាប់គាត់។ អ៊ីចឹងហេតុអីបានជាលោកស្រីពេលហ្នឹង មិនបានប្រាប់គាត់ទៅថាអ្នកទាំងអស់ហ្នឹងមកធ្វើទស្សនកិច្ច ហើយឲ្យគាត់កត់ចូលទៅ?

**ឆ៖** ចាស នាងខ្ញុំភ្លេច។

**ស៖** យើងមានឯកសារមួយនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥។ ឯកសារនេះ លោកស្រីបានផ្ដល់ព័ត៌មានបន្ថែមដោយបញ្ជាក់អំពីទស្សនកិច្ចនេះ។ តើលោកស្រីអាចឆ្លើយបញ្ជាក់បានទេថា តើហេតុដូចម្ដេចបានជាលោកស្រីនឹកឃើញពីទស្សនកិច្ចនៅឆ្នាំ៧៧ ហ្នឹង? តើលោកស្រីផ្ទាល់ទេ ជាអ្នកទាក់ទងមេមេធាវីលោកស្រី ឬក៏មានអ្នកណាមកជួបលោកស្រី មកសួរឲ្យលោកស្រីរំឭកការចងចាំវិញអំពីទស្សនកិច្ចនៅឆ្នាំ១៩៧៧នេះ?

**ឆ៖** ចាស អត់មានទេ ខ្ញុំផ្ទាល់។

**ស៖** លោកស្រីបានឆ្លើយជាមួយនឹងសហព្រះរាជអាជ្ញាអំពីស្ត្រីមួយរូបដែលឈ្មោះ ជូ គឹមឡូន។ លោកស្រីថា ជូ គឹមឡូន ក៏មានវត្តមានដែរនៅថ្ងៃនោះ គឺនៅការដ្ឋានដែលមេដឹកនាំមកធ្វើទស្សនកិច្ចនោះ។ អ៊ីចឹង តើខ្ញុំយល់អំពីចម្លើយរបស់លោកស្រីហ្នឹងត្រឹមត្រូវដែរឬទេ?

[១១:៤៧:២៤]

**ឆ៖** ចាស ជូ គឹមឡូន ថ្ងៃហ្នឹងក៏គាត់ឃើញដែរ ព្រោះគាត់នៅកងផ្សេងគ្នា ប៉ុននៅជិតៗគ្នា។

**ស៖** តើត្រឹមត្រូវដែរឬទេថា ជូ គឹមឡូន កើតនៅក្នុងភូមិជាមួយលោកស្រី<គឺភូមិធ្នង់រលើង> ហើយសព្វថ្ងៃនេះ ក៏ គាត់រស់នៅក្នុងភូមិជាមួយលោកស្រីដែរ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** តើលោកស្រីឃើញគាត់ញឹកញាប់ទេ?

**ឆ៖** ចាស ឃើញញឹកញាប់។

**ស៖** តើលោកស្រីធ្លាប់និយាយជាមួយគាត់ ពាក់ព័ន្ធទៅនឹងទស្សនកិច្ចនៅឆ្នាំ១៩៧៧ ហ្នឹងទេ?

**ឆ៖** យូរៗជួបគាត់ម្ដងហ្នឹង និយាយដែរប៉ុន្តែអត់ប៉ិាននេះផង និយាយស្ងាត់ៗ ខ្ញុំខ្លាច។ កងផ្សេងគ្នា។

**ស៖** លោកស្រីមានបាននិយាយអំពីសក្ខីកម្មរបស់គាត់នៅចំពោះមុខតុលាការហ្នឹងទេ?

**ឆ៖** ខ្ញុំអត់ដែរចូលសក្ខីកម្ម ទើបតែចូលថ្ងៃហ្នឹង ចូលតែខាងក្រោយ ស្ដាប់។

**ស៖** ខ្ញុំមិនមែនសួរអ៊ីចឹងទេ។ ខ្ញុំមិនបានសួរថាលោកស្រីធ្លាប់ផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការនេះទេ ខ្ញុំចង់សួរថាតើលោកស្រីធ្លាប់ពិភាក្សាជាមួយ ជូ គឹមឡូន អំពីការផ្តល់សក្ខីកម្មរបស់គាត់កាលពីថ្ងៃទី២៧ មករា ឆ្នាំ២០១៥នោះ ដែលគាត់ពេលហ្នឹងក៏គាត់បាននិយាយអំពីទស្សនកិច្ចរបស់មេដឹកនាំនៅត្រាំកក់ក្នុងឆ្នាំ១៩៧៧។ អ៊ីចឹងខ្ញុំចង់ដឹងថាលោកស្រីមានបាននិយាយជាមួយគាត់ទេ អំពីសក្ខីកម្មរបស់គាត់ មិនមែនសក្ខីកម្មរបស់លោកស្រីទេ?

**ឆ៖** ខ្ញុំអត់បាននិយាយជាមួយគាត់ទេ។ គាត់ផ្សេង ខ្ញុំផ្សេង។

[១១:៥០:០០]

**ស៖** តើនៅពេលណាដែលលោកស្រីបាន -- ខ្ញុំចង់សួរអ៊ីចេះវិញ តើលោកស្រីទាក់ទងអ្នកណាដើម្បីផ្តល់ព័ត៌មានបន្ថែមស្តីពីទស្សនកិច្ចរបស់ ប៉ុល ពត, នួន ជា, ខៀវ សំផន នៅត្រាំកក់ហ្នឹង? លោកស្រីបានទាក់ទងមេធាវីរបស់លោកស្រីនៅពេលណា? ឬក៏ទាក់ទងអ្នកណាផ្សេងទៀត<ពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានបន្ថែមនេះ? តើ>នៅពេលណា?

**ឆ៖** ខ្ញុំអត់មានទាក់ទងអ្នកណា ខ្ញុំ ខ្លួនខ្ញុំផ្ទាល់។

**ស៖** អ៊ីចឹង តើលោកស្រីផ្តល់ព័ត៌មានហ្នឹងទៅអ្នកណា?

**ឆ៖** ខ្ញុំដូចខ្ញុំជម្រាបអ៊ីចឹង ខ្ញុំមកអ៊ីចឹងខ្ញុំដាក់កន្លែង ខ្ញុំអត់ការចងចាំ អត់ស្គាល់កន្លែងទៀត ខ្ញុំមកដាក់ ហើយខ្ញុំឱ្យគេជួយអានឯកសារហ្នឹង ហើយខ្ញុំឱ្យអ្នកសរសេរឱ្យខ្ញុំប្រាប់សម្តីខ្ញុំចេញប្រាប់ ប្អូននៅអ៊ីចឹង បងប្អូនអ៊ីចឹង អ្នកចេះៗ។

**ស៖** នេះគឺជាលើកទី១ ដែលលោកស្រីបានបំពេញទម្រង់បែបបទនៅឆ្នាំ២០១០ ក៏ប៉ុន្តែខ្ញុំចង់និយាយអំពីពេលដែលលោកស្រីផ្តល់ព័ត៌មានបន្ថែម លោកស្រីបានចុះហត្ថលេខាលើឯកសារបន្ថែមគឺលេខ E344.1 នេះជាព័ត៌មានបន្ថែមទៅលើព័ត៌មានដើម ដែលធ្វើនៅចំពោះមុខវត្តមានមេធាវីរបស់លោកស្រី។ អ៊ីចឹងខ្ញុំចង់ដឹងថាតើនៅពេលណាដែលលោកស្រីបានទាក់ទងមេធាវីរបស់លោកស្រីដើម្បីផ្តល់ព័ត៌មានបន្ថែម?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១១:៥២:១៨]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមរំឭកបន្តិចពីព្រោះថានៅក្នុងសំណើរបស់យើងដែលលេខ E344 នោះយើងបានដាក់ -- យើងបានបញ្ជាក់ច្បាស់ហើយ ថាយើងទទួលព័ត៌មាន<បន្ថែម>ដោយរបៀបណា គឺថាព័ត៌មានហ្នឹងយើងបានបញ្ជាក់ហើយថា ជូ គឹមឡុន ជាអ្នកផ្ដល់ព័ត៌មាន<ដែរ>។ <ខ្ញុំដឹងថាគ្រប់ភាគីចង់សួរសំណួរលើបញ្ហានេះ> អ៊ីចឹងយើងបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសំណើហ្នឹង ថាមូលហេតុអីបានជាយើងដឹងអំពីព័ត៌មានបន្ថែមហ្នឹង?

**កញ្ញា អង់តា ហ្គីសសេ៖**

ក៏ប៉ុន្តែ ខ្ញុំមិនមែនសួរចង់ដឹងថាតើលោកស្រីមេធាវីខ្លួនឯងហ្នឹងដឹងអំពីសក្ខីកម្មហ្នឹងបែបណាទេ ខ្ញុំសួរទៅលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដើម្បីដឹងថាតើហេតុដូចម្ដេចបានជាគាត់ទាក់ទងមេធាវីរបស់គាត់នោះ? ហើយហេតុម៉េចបានជាគាត់អាចទៅពិភាក្សាអំពីខ្លឹមសារ អំពីសក្ខីកម្មរបស់ ជូ គឹមឡុននោះ? <ជាសក្ខីកម្មដែលយឺតបន្តិចនៅក្នុងថ្ងៃនេះ> អ៊ីចឹងខ្ញុំគិតថាខ្ញុំមានសិទ្ធិក្នុងការសួរដើម្បីស្វែងរកការពិត ហើយនិងដើម្បីឲ្យមានភាពជឿជាក់បាន។ ខ្ញុំមិនៗបានថា សហមេធាវីនាំមុខមិនៗមានតម្លាភាពអីទេ ខ្ញុំចង់បានចម្លើយពីដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកស្រីមេធាវី អង់តា ហ្គីសសេ <ការតាំងសំណួររបស់>លោកស្រី <គឺខ្ញុំយល់ថា>លោកស្រី<បានសួរសំណួរជាច្រើន> ជាពិសេសការសម្ងាត់រវាងការទាក់ទងគ្នារវាងដើមបណ្ដឹង ហើយនិងមេធាវី។ <សូមកុំភ្លេចថាដើមបណ្ដឹងរដ្ឋប្បវេណីមានមេធាវីរបស់គាត់។> លោកស្រីសួរថា តើគាត់ទាក់ទងជាមួយមេធាវីយ៉ាងម៉េចនោះ គឺមានបញ្ហាហើយ យើងមិនអាចចោទសួរពីការសម្ងាត់ហ្នឹងទេ។

[១១:៥៤:១២]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំ<>មិនបានសួរគាត់ឲ្យគាត់បញ្ជាក់ថាតើគាត់និយាយយ៉ាងម៉េចៗនៅក្នុងឯកសារហ្នឹងទេ ក៏ប៉ុន្តែ<ដោយសារយើងនិយាយអំពីតម្លាភាព ហើយ>នៅក្នុងសំណើហ្នឹងគឺថាវាមិនមែនជាការសម្ងាត់ទេ <>មេធាវីគាត់បញ្ជាក់ច្បាស់អម្បាញ់មិញហើយថាមិនមែនជាការសម្ងាត់ទេ គឺមានការពិភាក្សាគ្នាមែន

រវាងអង្គហេតុថ្មីនេះ។ អ៊ីចឹងខ្ញុំចង់ដឹងពីព្រោះថាទើបតែឆ្នាំ២០១៥ហ្នឹងទេបានមានឯកសារហ្នឹងនៅក្នុងសំណុំរឿង ហើយគាត់ៗដាក់ពាក្យតាំងសុំខ្លួនតាំងពីឆ្នាំ២០១០ឯណោះ។ អ៊ីចឹង ខ្ញុំ<មានសិទ្ធិដើម្បី>ដឹងថាតើនៅពេលណាដែលគាត់អាចចងចាំឡើងវិញអំពីហេតុការណ៍ថ្មីហ្នឹង? អ៊ីចឹងខ្ញុំចង់ដឹងថាតើវាមានទំនាក់ទំនងជាមួយនឹងការជជែកគ្នាជាមួយលោកស្រី ជូ គឹមឡុន អត់ដើម្បីឲ្យដឹងថាតើសក្ខីកម្មរបស់គាត់មានសុចរិតភាពអត់ ខ្ញុំមិនបានសួរពីការសម្ងាត់ដាច់ខាតនោះទេ។ ដូចជាមេធាវីបានប្រាប់ហើយថាព័ត៌មានវាមាននៅក្នុងសំណើហើយ ក៏ប៉ុន្តែខ្ញុំៗចង់ដឹងព័ត៌មានពីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់នេះ ថាតើគាត់អាចនឹកឃើញឡើងវិញយ៉ាងម៉េច ហើយគាត់ទាក់ទងអ្នកណាដើម្បីផ្តល់ព័ត៌មានបន្ថែមនេះ។ អ៊ីចឹងខ្ញុំចង់ដឹងថាគាត់ជាអ្នកនិយាយខ្លួនឯងផ្ទាល់ ឬក៏មានអ្នកណាជាអ្នកទាក់ទងឲ្យគាត់អំពីព័ត៌មានថ្មីនេះ។ <ថាតើគួរឲ្យជឿជាក់បានឬក៏អត់? ក្នុងនាមជាមេធាវីការពារក្តី ខ្ញុំមិនអាចយល់ស្របទៅតាមការតាំងសំណួរដែលគេប្រាប់ទេ បើធ្វើអ៊ីចឹង ខ្ញុំក៏មិនមានហេតុផលអ្វីដែលត្រូវនៅក្នុងសវនាការនេះដែរ។> អ៊ីចឹងខ្ញុំគិតថា ខ្ញុំអាចសួរបាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកស្រីៗ គាត់ៗមានមេធាវីរបស់គាត់ អ៊ីចឹងនៅពេលដែលលោកស្រីសួរ គឺអាចទាក់ទងនឹងមេធាវីគាត់។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសួរហ្នឹង <ខ្ញុំមិនដឹងថាតើមេធាវីរបស់គាត់គឺជាអ្នកដែលសួរគាត់បន្ថែមមែនឬក៏អត់> គឺថាអ្នកណាជាអ្នកទាក់ទងគាត់ដើម្បីទទួលបានព័ត៌មានបន្ថែមហ្នឹង។ ខ្ញុំគិតថាដូចជាអត់មានការសម្ងាត់អីទេ។ ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងការសម្ងាត់នៃព័ត៌មាននេះ គឺមិនមានបញ្ហាអី ព្រោះថា យើងមានឯកសារផ្តល់ជូនទៅភាគីទាំងអស់ហើយ ហើយឯកសារទាំងអស់ហ្នឹងក៏បានបញ្ជាក់យ៉ាងច្បាស់ថា មានការទាក់ទងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ អ៊ីចឹង ខ្ញុំគិតថា ខ្ញុំមានសិទ្ធិនៅក្នុងការសួរសំណួរបែបនេះហើយលោកចៅក្រម។

[១១:៥៦:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ ដើម្បីបញ្ជាក់សំណួររបស់លោកចៅក្រម ឡាវែន៍ បន្ថែមទៅលើឯកសារ E344.1 នេះ ឯកសារនេះពុំមានបញ្ជាក់ថា ធ្វើឡើងដោយមេធាវីទេ ហើយឈ្មោះដែលមាននៅក្នុងនេះក៏ជាឈ្មោះថ្មីមួយដែលយើងអាចត្រូវសួរបញ្ជាក់បន្ថែមពីរបៀបនៃការធ្វើឯកសារនេះបានដែរ។ ដូច្នេះ វាអត់មានអ្វីដែលជាអាថ៌កំបាំងរវាងទំនាក់ទំនងវិជ្ជាជីវៈមេធាវីជាមួយនឹងកូនក្តីនៅក្នុងឯកសារនេះទេ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៧:៤១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ដើម្បីកុំឲ្យ>ខាតពេលវេលា។ យើងនឹងសុំឲ្យ<សហ>មេធាវី<នាំមុខ>ទាំងអស់គ្នាហ្នឹងលើកដៃឡើង បើសិនជាមានបញ្ហាអី<ជាការរំលោភបំពានណាមួយ។ សូមបន្តទៅមុខទៀត>។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកស្រី អ៊ុង សារឿន លោកស្រីទើបតែបាននិយាយថា លោកស្រីខ្លួនឯងផ្ទាល់មកទីនេះដើម្បីផ្តល់ព័ត៌មានថ្មីទាក់ទងនឹងទស្សនកិច្ចនៅឆ្នាំ១៩៧៧។ ខ្ញុំយល់យ៉ាងដូច្នេះ ត្រឹមត្រូវដែរឬទេ?

**លោកស្រី អ៊ុង សារឿន៖**

**ឆ៖** ចាស ខ្លួនខ្ញុំផ្ទាល់ មក។

**ស៖** តើក្រោយពីពេលដែលលោកស្រីពិភាក្សាជាមួយលោកស្រី គីមឡុន ក្រោយពិភាក្សាជាមួយគាត់ហើយ បានលោកស្រីសម្រេចចិត្តថា នឹងផ្តល់ព័ត៌មានបន្ថែមជូនតុលាការ ឬក៏យ៉ាងណា?

**ឆ៖** ចាស។

**ស៖** លោកស្រីបានឆ្លើយថាលោកស្រីបានឃើញមេដឹកនាំខ្មែរក្រហមមកកន្លែងលោកស្រីធ្វើការ។ លោកស្រីបានប្រាប់ថា តាម៉ុក បានមកជិះឡានមួយ ហើយមានឡានមួយទៀតផងដែរ។ តើខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ លោកស្រីបានឆ្លើយយ៉ាងដូច្នេះ?

**ឆ៖** ខ្ញុំអត់ទាន់យល់។

[១២:០០:០០]

**ស៖** នៅថ្ងៃនោះ តើនៅថ្ងៃដែលលោកស្រីបានជួបមេដឹកនាំខ្មែរក្រហមនោះ តើលោកស្រីបាន

ឃើញឡានប៉ុន្មាន?

**ឆ៖** ចាស ខ្ញុំឃើញឡានពីរ។

**ស៖** តើលោកស្រីមានឃើញមេដឹកនាំខ្មែរក្រហមចុះពីលើឡានដែរឬទេ?

**ឆ៖** ខ្ញុំ អត់បាន -- ពេលចុះហ្នឹងអត់បានឃើញគាត់ចុះពីឡានណាៗ គ្រាន់តែឃើញឡានពីរ ព្រោះខ្ញុំខំពលកម្មរែកដី រែកទៅឃើញគាត់ចុះដើរ។

**ស៖** តើលោកស្រីបានឃើញមេដឹកនាំប៉ុន្មាននាក់ដែរនៅថ្ងៃនោះ?

**ឆ៖** ចាស ថ្ងៃនោះ ឃើញប្រាំនាក់ មេឃុំម្នាក់។

**ស៖** លោកស្រីបានប្រាប់ថាលោកស្រីបានឃើញ តាសាន។ លោកស្រីនៅរក្សាចម្លើយលោកស្រីនេះដែរឬទេ?

**ឆ៖** ចាស តាសាន ខ្ញុំធ្លាប់ឃើញ ព្រោះគាត់ចេញចូលក្នុងភូមិហ្នឹង គាត់មានបងប្អូនគាត់នៅឃុំលាយបូរហ្នឹង ញឹកញាប់។

**ស៖** តើលោកស្រីអាចបញ្ជាក់ពីពេល លើកទី១ដែលលោកស្រីបានឃើញ តាសាន នៅភូមិលោក<ស្រី>នោះ ឃើញនៅពេលណាដែរ?

**ប្រធានអង្គជំនុំ៖**

ទំនងជាអស់ពេលហើយឥឡូវ មេធាវី។

**សួរដោយកញ្ញា អង់តា ហ្គីសេ៖**

**ស៖** លោកស្រី អ៊ុំង សារឿន លោកស្រីបានឃើញ តាសាន ជាច្រើនដងកន្លងមកហើយ មុននឹងបានឃើញគាត់នៅថ្ងៃទស្សនកិច្ចនៅឆ្នាំ១៩៧៧ហ្នឹង។ តើត្រឹមត្រូវដែរឬទេ?

**លោកស្រី អ៊ុំង សារឿន៖**

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** នៅពេលដែលលោកស្រីឃើញគាត់នៅក្នុងភូមិលោកស្រីនោះ តើគាត់មានមុខតំណែងអ្វីដែរ? គឺថា មើលឃើញគាត់មុនទស្សនកិច្ចឆ្នាំ១៩៧៧នោះ គាត់មានមុខតំណែងជាអ្វីដែរ?

[១២:០២:៥៤]

**ឆ៖** ខ្ញុំអត់ដឹងគាត់មុខតំណែងអី ប៉ុន្តែថាអង្គការ គាត់ឃុំ អត់ដឹង អត់ចងចាំរឿងតំណែងអី ខ្ញុំអត់ស្គាល់។

**ប្រធានអង្គជំនុំ៖**

អស់ពេលលោកស្រីមេធាវី។

មន្ត្រីរដ្ឋបាលតុលាការ ចាត់ចែងសម្របសម្រួលជាមួយនឹងអ្នកបច្ចេកទេស ដើម្បីប្តូរ ឌី.វី.ឌី។

លោកស្រី អ៊ុំង សារឿន ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គជំនុំជម្រះស្តាប់ អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ ចំពោះលោកស្រីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្តនិងជាសមូហភាពពីជនជាប់ចោទ និងពីស្ថានភាពព្យសនកម្មដែលមានជាអាទិ៍ ចំពោះលោកស្រីដូចជាការខាត ខូចខាតខាងរាងកាយសម្ភារៈ ឬផ្លូវចិត្ត ឬផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋព្យសនកម្មផ្ទាល់ និងបានកើតឡើងពិតប្រាកដមកទល់ពេលបច្ចុប្បន្ននេះ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

**លោកស្រី អ៊ុំង សារឿន៖**

ចាស នាងខ្ញុំសុំសំណងឯកជន ខូចខាតផ្ទះសម្បែង សម្ភារៈអស់ នាងខ្ញុំ ទាំងកូនទាំងប្តី បងប្អូនទាំងអស់។

**ប្រធានអង្គជំនុំ៖**

មិនមានអីត្រូវតទៀតទេ?

**លោកស្រី អ៊ុំង សារឿន៖**

សំណួរទី១ នាងខ្ញុំ ហេតុអ្វីបានខ្ញុំធ្វើការពលកម្មលំបាក ហេតុអ្វីបានមិនឲ្យខ្ញុំហូបឆ្អែត? សំណួរទី២ ហេតុអីបានយកសាច់ញាតិ គ្រួសារខ្ញុំ កូន ឪពុកម្តាយសម្លាប់? សំណួរទី៣ ហេតុអ្វីបានសម្លៀកបំពាក់ ស្លៀកពាក់មិនគ្រប់គ្រាន់? ខ្ញុំអស់ហើយ។

**ប្រធានអង្គជំនុំ៖**

លោកស្រីតាំងសំណួរនេះ សំណួរទៅសំដៅលើជនជាប់ចោទអ៊ីចឹងទេ ឬក៏សួរមកអង្គជំនុំជម្រះ?

**លោកស្រី អ៊ុំង សារឿន៖**

សួរខាងជាប់ចោទ។

[១២:០៧:១៣]

**ប្រធានអង្គជំនុំ៖**

បាទ ចំពោះបញ្ហានេះ អង្គជំនុំជម្រះសូមជម្រាបជូនលោកស្រី អ៊ុង សារឿន ថានៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ជនជាប់ចោទទាំងពីរឆ្លើយបញ្ជាក់អំពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបមក អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល។ លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្តីឱ្យជនជាប់ចោទ។

នៅក្នុងសវនាការថ្ងៃនោះ អង្គជំនុំជម្រះបានកំណត់ឱ្យជនជាប់ចោទ ឬ/និងមេធាវីការពារក្តីរបស់ជនជាប់ចោទត្រូវមានការទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយបតទៅនឹងសំណួរនៅដំណាក់កាលមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ ដែលសួរឡើងដោយអង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធ។

[១២:០៨:១៥]

រហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបមកជាការយល់ព្រមឆ្លើយតបនឹងសំណួរនៅឡើយទេ។ សូមលោកស្រីជ្រាប។

បាទ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី៣០ ខែមីនា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃចន្ទនេះ ចន្ទសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ឌុងម៉ាន ដែលនឹងត្រូវធ្វើតាមរយៈមធ្យោបាយសោតទស្សន៍ពីសហរដ្ឋអាមេរិក។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។ ហើយអង្គជំនុំជម្រះក៏សូមរំឭកផងដែរថាសវនាការស្តាប់សក្ខីកម្មសាក្សី ឌុងម៉ាន ត្រូវធ្វើតែនៅពេលព្រឹក ដោយចាប់ផ្តើមពីម៉ោងប្រាំបីរហូតដល់ម៉ោងដប់ព្រឹក ពីថ្ងៃចន្ទ ទី៣០ ខែមីនា រហូតដល់ថ្ងៃទី០២ ខែមេសា។ សូមភាគីជ្រាប។

សូមអញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ<មានសំណើ>មួយ<ទាក់ទង>ទៅនឹងសាក្សី<ដែលនឹងត្រូវមកផ្តល់សក្ខីកម្មក្នុងពេលខាងមុខ គឺ> រីឆាដ ឌុដម៉ាន។ យើងទើបតែបានទទួលអ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់កាលពី២០នាទីមុននេះ។ នៅក្នុងអ៊ីម៉ែលនេះ គឺមានសរសេរថារបៀបវារៈការសួរសំណួរសាក្សីនេះបានផ្លាស់ប្តូរហើយ។ <ដូចអង្គជំនុំជម្រះបានដឹងហើយថាយើងបានស្នើសុំសាក្សីរូបនេះ> អ៊ីចឹងខ្ញុំទាញការសន្និដ្ឋាន<ពីអ៊ីម៉ែល>ថាអង្គជំនុំជម្រះនឹងចាប់ផ្តើមសួរមុនគេ ហើយបន្ទាប់មកព្រះរាជអាជ្ញា ហើយ<បន្ទាប់មកគឺខាង>មេធាវីការពារក្តី។ អ៊ីចឹងដោយសារ<តែមានការកែប្រែដំណើរការអនុវត្តនីតិវិធីនេះ គឺ>មានការប្រែប្រួលលំដាប់លំដោយនៃការចោទសំណួរសាក្សីនេះ ខ្ញុំសួរថាមូលហេតុអ្វីក៏ចាំបាច់កែប្រែ ហើយមានអ្វីទៅពីក្រោយការកែប្រែនេះបាទ?

**ប្រធានអង្គជំនុំ៖**

បាទ នេះជាការងាររៀបចំសវនាការរបស់អង្គជំនុំជម្រះ ដោយកាលពីមុនអង្គជំនុំជម្រះមិនបាន មិនទាន់បានគិតគូរដល់បញ្ហាលទ្ធភាពក្នុងការខ្លួន តាំងសំណួរ អ៊ីចឹងហើយបានជាការពិភាក្សាចុងក្រោយចៅក្រមមានបំណងក្នុងការតាំងសំណួរដោយពេលវេលាចង្អៀតសម្រាប់សួរ ស្តាប់សក្ខីកម្មសាក្សីរូបនេះដោយកំណត់ពេលវេលាតែបីថ្ងៃប៉ុណ្ណោះ។ អ៊ីចឹងហើយបានជាយើងធ្វើការរៀបចំពិនិត្យឡើងវិញ ហើយការរៀបចំនេះគឺយើងជាប្រធានអង្គជំនុំជម្រះបានគិតគូរពីបញ្ហានេះ ថាតើគួររៀបចំយ៉ាងម៉េចឲ្យមានប្រសិទ្ធភាព ហើយនិងឲ្យប្រព្រឹត្តទៅបានចប់ចុង ចប់ដើម ក្នុងលក្ខណៈដែលស្តាប់សក្ខីកម្មសាក្សីដែលមានអាយុ៩៥ឆ្នាំហើយនោះ។ វាមិនល្អទេ ប្រសិនបើយើងធ្វើតាមពេលវេលាដែលបានកំណត់បីថ្ងៃនេះវាមិនចប់នោះ។

បាទនេះជាការរៀបចំ សិទ្ធិក្នុងសម្រេចដោយឆន្ទានុសិទ្ធិក្នុងការរៀបចំដំណើរការស្តាប់សក្ខីកម្មសាក្សីនៅក្នុងអង្គជំនុំជម្រះ។ ដូចជាការកំណត់ពេលវេលា ការបែងចែកពេលវេលាកន្លងមកសម្រាប់សាក្សីនីមួយៗ ដូចជាអង្គជំនុំជម្រះមិនចាំបាច់ស្តាប់តាមការសម្រេចរបស់ភាគីទេ មិនបាច់តាមសំណើសុំរបស់ភាគីទេ អង្គជំនុំជម្រះពិចារណា ហើយកំណត់ការបែងចែកពេលវេលាសមស្របដើម្បីស្តាប់សក្ខីកម្មសាក្សីតែម្តង។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំមិនមានការកត់សម្គាល់អីការអធិប្បាយនោះទេ ក៏ប៉ុន្តែ យើងមិនជំទាស់ហ្នឹងនេះទេ លំដាប់លំដោយនេះទេ ទោះបីជាថា -- ទោះឲ្យមេធាវីការពារក្ដីសួរសំណួរ បន្តពីអង្គជំនុំជម្រះក៏ដោយ យើងអត់មានជំទាស់អ្វីទេលោកប្រធាន<បើសិនយើងឃើញថាវាសមហេតុ សមផល>។ ស្រេចតែអង្គជំនុំជម្រះអ្នកសម្រេចលំដាប់លំដោយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ចំពោះយើងក៏ដូចគ្នាដែរ យើងថាឲ្យមេធាវីការពារក្ដីសួរបន្ទាប់ពីអង្គជំនុំជម្រះក៏មិនអីដែរចំពោះ យើងលោកប្រធាន យើងមិនមានការជំទាស់អ្វីទេ។

[១២:១៣:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អ៊ីចឹងគឺការរៀបចំមិនមានបញ្ហាអ្វីធំដុំទេ យើងនឹងសម្រេចជាក់ស្ដែងនៅថ្ងៃច័ន្ទតែ ម្ដង។ បាទ សូមជម្រាបឡើងវិញថា អំមិញថាមានការភ័ន្តច្រឡំថ្ងៃ។ អ៊ីចឹងសវនាការហ្នឹងបីថ្ងៃ គឺថ្ងៃ ៣០, ៣១ ខែមីនា ហើយនិងថ្ងៃ០១ ខែមេសា ឆ្នាំ២០១៥ នេះតាមការស្ដាប់សក្ខីកម្មសាក្សី ឌុដម៉ាន ដែល មានរយៈពេលពីរម៉ោងក្នុងមួយថ្ងៃ ហើយធ្វើតែនៅពេលព្រឹកទេ។

អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រី អ៊ុង សារឿន ដែលបានផ្ដល់សក្ខីកម្មចំពោះមុខអង្គ ជំនុំជម្រះក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរយៈពេលបន្ថែមកន្លះថ្ងៃមកនេះ។ សក្ខីកម្មរបស់លោក ស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ ការស្ដាប់ ផ្ដល់សក្ខីកម្មរបស់លោកស្រី បានដល់ទីបញ្ចប់ហើយ វត្តមានរបស់លោកស្រីលែង -- នៅអ.វ.ត.កនេះ លែងមានភាពចាំបាច់ទៀត ហើយ លោកស្រីអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោកស្រី ឬក៏ទីណាជាគោលដៅដែលលោកស្រី មានបំណងចង់ទៅបានហើយ។ សូមលោកស្រីវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោកស្រី អ៊ុង សារឿន វិលត្រឡប់ទៅកាន់លំនៅឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់ មានបំណងចង់ទៅបានហើយ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង អ.វ.ត.ក នាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់ មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញ

01468804


នៅព្រឹកថ្ងៃចន្ទ ទី៣០ ខែមីនា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបីព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

*(សវនាការផ្អាកនៅម៉ោង ១២:១៤ នាទី)*